ក

# មាតិកា

## I- ខុទ្ទកាល័យព្រះមហាក្សត្រ

### ១-ព្រះរាជក្រឹត្យ


| | | |
|---|---|---|
| ២២-៣-២០០០ | - ព្រះរាជក្រឹត្យ នស/រកត/០៣០០/១២៥ តែងតាំងឯកឧត្តម ចាន់ ជឿន ជាទីប្រឹក្សាសម្តេច ហេង សំរិន អនុប្រធានទី១ រដ្ឋសភា | ៤៩៩ |
| ២២-៣-២០០០ | - ព្រះរាជក្រឹត្យ នស/រកត/០៣០០/១២៦ តែងតាំងឯកឧត្តម មាស សន្ធា ជាទីប្រឹក្សាសម្តេច ហេង សំរិន អនុប្រធានទី១ រដ្ឋសភា | ៥០០ |
| ២២-៣-២០០០ | - ព្រះរាជក្រឹត្យនស/រកត/០៣០០/១២៧ តែងតាំងឯកឧត្តម នូ សុវណ្ណារ៉ា ជាទីប្រឹក្សាសម្តេច ហេង សំរិន អនុប្រធានទី១ រដ្ឋសភា | ៥០១ |
| ២២-៣-២០០០ | - ព្រះរាជក្រឹត្យ នស/រកត/០៣០០/១២៨ តែងតាំងឯកឧត្តម ម៉ុន សំបូរ ជាទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី | ៥០២ |
| ២២-៣-២០០០ | - ព្រះរាជក្រឹត្យ នស/រកត/០៣០០/១២៩ តែងតាំងឯកឧត្តម ឌួង រតនា ជាទីប្រឹក្សាផ្ទាល់ សម្តេចនាយករដ្ឋមន្ត្រី | ៥០៣ |
| ២២-៣-២០០០ | - ព្រះរាជក្រឹត្យ នស/រកត/០៣០០/១៣០ តម្លើងឋានន្តរសក្តិ ថ្នាក់ឧត្តម សេនីយ៍ត្រី ជូនវរសេនីយ៍ឯក ហ៊ុន ស៊ីថា | ៥០៤ |
| ២២-៣-២០០០ | - ព្រះរាជក្រឹត្យ នស/រកត/០៣០០/១៣១ អនុញ្ញាតជូនឯកឧត្តម ខូន សឿ ជាទីប្រឹក្សាអាជ្ញាធរជាតិប្រឆាំងគ្រឿងញៀន ឈប់លែងពីមុខតំណែង | ៥០៥ |
| ២២-៣-២០០០ | ព្រះរាជក្រឹត្យ នស/រកត/០៣០០/១៣២ តែងតាំងឯកឧត្តម ស៊ា គួសេង ជាទីប្រឹក្សាក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | ៥០៦ |
| ២២-៣-២០០០ | - ព្រះរាជក្រឹត្យ នស/រកត/០៣០០/១៣៣ តែងតាំងឯកឧត្តម សូ គឹមអាន ជាអគ្គលេខាធិការរងរាជរដ្ឋាភិបាលកម្ពុជា | ៥០៧ |
| ២២-៣-២០០០ | - ព្រះរាជក្រឹត្យ នស/រកត/០៣០០/១៣៤ តែងតាំងមុខងារ និង តម្លើង ឋានន្តរសក្តិជូននាយទាហានជាន់ខ្ពស់ នៃកងយោធពលខេមរភូមិន្ទ | ៥០៨ |


## II- រាជរដ្ឋាភិបាល

### ១-អនុក្រឹត្យ


| | | |
|---|---|---|
| ២២-៣-២០០០ | - អនុក្រឹត្យ លេខ ១១ អនក្រ.បក ស្តីពីនីតិវិធីនៃការកសាងប្លង់ សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី | ៥០៩ |

២២-៣-២០០០ - អនុក្រឹត្យ លេខ ១២ អនក្រ.បក ស្តីពីការបង្កើតរចនាសម្ព័ន្ធនៃក្រុម ប្រឹក្សារំសាយ កងកំលាំងប្រដាប់អាវុធ ៥១៦

២២-៣-២០០០ - អនុក្រឹត្យ លេខ១៣ អនក្រ.បក ស្តីពីការបង្កើតគណៈកម្មការ អតីតយុទ្ធជនខេត្ត ៥២២

២០-៣-២០០០ - អនុក្រឹត្យ លេខ ១០៧ អនក្រ.តត ស្តីពីការតែងតាំង និងផ្លាស់ប្តូរ មុខងារនាយទាហាននៃកងយោធពលខេមរភូមិន្ទ ៥២៥

២១-៣-២០០០ - អនុក្រឹត្យ លេខ ១០៨ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៥៣៣

២១-៣-២០០០ - អនុក្រឹត្យ លេខ ១០៩ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៥៣៤

២១-៣-២០០០ - អនុក្រឹត្យ លេខ ១១០ អនក្រ.តត ស្តីពីការជូនមេដាយគេហមេត្រី ៥៣៥

២២-៣-២០០០ - អនុក្រឹត្យ លេខ ១១១ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៥៣៦

២២-៣-២០០០ - អនុក្រឹត្យ លេខ ១១២ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៥៣៧

២៣-៣-២០០០ - អនុក្រឹត្យ លេខ ១១៣ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៥៣៨

២៣-៣-២០០០ - អនុក្រឹត្យ លេខ ១១៤ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៥៣៩

២៣-៣-២០០០ - អនុក្រឹត្យ លេខ ១១៥ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៥៤០

២៣-៣-២០០០ - អនុក្រឹត្យ លេខ ១១៦ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៥៤១

២៣-៣-២០០០ - អនុក្រឹត្យ លេខ ១១៧ អនក្រ.តត ស្តីពីការជូនមេដាយសេរីមេត្រី ៥៤២

## ២-សារាចរណែនាំ

២២-៣-២០០០ - សារាចរណែនាំ លេខ ០៣ សរណន ស្តីពីការរៀបចំពិធីទិវាវប្បធម៌ជាតិ លើកទី២ នៃព្រះរាជាណាចក្រកម្ពុជា ៥៤៣

## III- ការងារបណ្តាក្រសួង

### ទីស្តីការរដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

### ប្រកាស

២១-៣-២០០០ - ប្រកាស លេខ ១៨៣ កឧ.ប្រក អនុញ្ញាតអោយក្រុមហ៊ុន វិនគ្គារ ប្លេអេន អ៊ិនដាស្ទ្រី តំណាងដោយលោកស្រី TANG YEN RAN សញ្ជាតិចិន (តៃវ៉ាន់) បង្កើតរោងចក្រកាត់ដេរសំលៀកបំពាក់នាំចេញ ៥៤៦

# ភី

២២-៣-២០០០ - ប្រកាស លេខ ១៩៨ កឧ.ប្រក អនុញ្ញាតអោយក្រុមហ៊ុន ព្រួត ឃ្វូញៀន (ខេមបូឌា) ហ្វាអេន ខូអិលធីឌី តំណាងដោយលោក LAM SIU MAN សញ្ជាតិចិន (ហុងកុង) បង្កើតរោងចក្រកាត់ដេរសំលៀកបំពាក់នាំចេញ ៥៥៧

# I- ខុទ្ទកាល័យព្រះមហាក្សត្រ

## ១-ព្រះរាជក្រឹត្យ

### ព្រះរាជក្រឹត្យ ជស/រកត/០៣០០/១២៥

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ រាជវរិវង្ស

ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

***

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញបទបញ្ជាផ្ទៃក្នុងរដ្ឋសភា ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

-បានឃើញសំណើរបស់សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ .- តែងតាំង លោកឧត្តម ចាន់ ជឿន ជាទីប្រឹក្សាសម្តេច ហេង សំរិន អនុប្រធានទី១ រដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា ទទួលបានប្រាក់បៀវត្ស មានឋានៈស្មើ អនុរដ្ឋលេខាធិការ ។

មាត្រា២ .- ប្រធានរដ្ឋសភា និងទីស្តីការគណៈរដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុក អនុវត្តព្រះរាជក្រឹត្យនេះ ។

មាត្រា៤ .- ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០០០

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

★★★

## ព្រះរាជក្រឹត្យ ជស/រកត/០៣០០/១២៦

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ រាជហរិវង្ស

ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

***

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងរដ្ឋសភា ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

-បានទ្រង់យល់សំណើរបស់សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ .-** តែងតាំង ឯកឧត្តម **មាស សុគ្គា** ជាទីប្រឹក្សាសម្តេច **ហេង សំរិន** អនុប្រធានទី១ រដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា ទទួលបន្ទុកកិច្ចការវិនិយោគ មានឋានៈស្មើ អនុរដ្ឋលេខាធិការ ។

**មាត្រា២ .-** ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ។

**មាត្រា៤ .-** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០០០

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

**ជា ស៊ីម**

***

## ព្រះរាជក្រឹត្យ ជស/រកត/០៣០០/១២៧

### យើង

### ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ រាជហរិវង្ស

### ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

### ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

### ព្រះចៅក្រុងកម្ពុជាធិបតី

***

-បានទ្រង់ទតព្រះរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់ទតព្រះរាជក្រមបញ្ញត្តិផ្លូវរដ្ឋសភា ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

-បានទ្រង់ទតសំណើរបស់សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា

### ត្រាស់បង្គាប់

**មាត្រា១ .-** តែងតាំង ឯកឧត្តម នូ សុវណ្ណារ៉ា ជាទីប្រឹក្សាសម្តេច ហេង សំរិន អនុប្រធានទី១ រដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា ទទួលបន្ទុកសង្គមកិច្ច មានឋានៈស្មើ រដ្ឋលេខាធិការ ។

**មាត្រា២ .-** ប្រធានរដ្ឋសភា និងអគ្គលេខាធិការដ្ឋានរដ្ឋសភា នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ។

**មាត្រា៤ .-** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០០០

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

**ជា ស៊ីម**

★★★

# ព្រះរាជក្រឹត្យ ជស/រកត/០៣០០/១២៨

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ រាជហរិវង្ស

## ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

## ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជាធិបតី

***

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/៩៤/០២ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-សេចក្តីតាមសំណើនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ ២០០០

## ត្រាស់បង្គាប់

**មាត្រា ១ .-** ត្រូវបានតែងតាំង ឯកឧត្តម ម៉ិន សំបូរ ជាទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា មានឋានៈស្មើ អនុរដ្ឋលេខាធិការ ។

**មាត្រា ២ .-** បទបញ្ញត្តិទាំងឡាយដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ .-** នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៤ .-** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០០០

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

★★★

# ព្រះរាជក្រឹត្យ ជស/រកត/០៣០០/១២៩

## យើង

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ រាជហរិវង្ស**
**ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម**
**ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**
**ព្រះចៅក្រុងកម្ពុជាធិបតី**

***

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/៩៤/០២ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-យោងតាមសំណើនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ ២០០០

## ត្រាស់បង្គាប់

មាត្រា ១ .- ត្រូវបានតែងតាំង ឯកឧត្តម **ឱុង រតនា** ជាទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា មានឋានៈស្មើ អនុរដ្ឋលេខាធិការ ។

មាត្រា ២ .- បទបញ្ញត្តិទាំងឡាយដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣ .- នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៤ .- ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០០០

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

**ជា ស៊ីម**

***

# ព្រះរាជក្រឹត្យ ជស/រកត/០៣០០/១៣០

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ រាជហរិវង្ស

ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

***

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/៩៤/០២ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើត ក្រសួងការពារជាតិ

-យោងតាមសំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ ២០០០

## ត្រាស់បង្គាប់

**មាត្រា ១ .-** ត្រូវបានតម្លើងឋានន្តរសក្តិ ថ្នាក់ឧត្តមសេនីយ៍ត្រី កងយោធពលខេមរភូមិន្ទ នៃអគ្គមេបញ្ជាការដ្ឋាន ជូនវរសេនីយ៍ឯក **ហ៊ិន ស៊ីថា** អត្តលេខ ០០៣២២២ បច្ចុប្បន្នជំនួយការសម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ។

**មាត្រា ២ .-** នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ .-** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០០០

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

**ជា ស៊ីម**

★★★

# ព្រះរាជក្រឹត្យ ជស/រកត/០៣០០/១៣១

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ រាជហរិវង្ស**

**ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម**

**ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

***

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/៩៤/០២ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-យោងតាមសំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

**ត្រាស់បង្គាប់**

មាត្រា ១ .- ត្រូវបានអនុញ្ញាតជូន ឯកឧត្តម ខួន ស៊ឿ ទីប្រឹក្សានៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនលាលែងពីមុខតំណែង ។

មាត្រា ២ .- នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ អោយបានសំរេច ។

មាត្រា ៣ .- ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០០០

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

★★★

# ព្រះរាជក្រឹត្យ ជស/រកត/០៣០០/១៣២

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ រាជហរិវង្ស

ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

***

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/៩៤/០២ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

-យោងតាមសំណើនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ .-** ត្រូវបានតែងតាំង ឯកឧត្តម ស៊ា គុសល បច្ចុប្បន្ន នាយកខុទ្ទកាល័យរដ្ឋមន្ត្រីការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ជាទីប្រឹក្សាក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បន្ថែមលើមុខងារបច្ចុប្បន្ន ដោយមានឋានៈស្មើ អគ្គនាយក ។

**មាត្រា ២ .-** នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ឱ្យបានសំរេច ។

**មាត្រា ៣ .-** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០០០

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

**ជា ស៊ីម**

★★★

# ព្រះរាជក្រឹត្យ ជស/រកត/០៣០០/១៣៣

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ រាជហរិវង្ស

ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

***

-បានទ្រង់ទតរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់ទតព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់ទតព្រះរាជក្រមលេខ នស/រកម/៩៤/០២ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់ទតព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី

-យោងតាមសំណូមពររបស់ រាជរដ្ឋាភិបាល

## ត្រាស់បង្គាប់

**មាត្រា ១ .-** តែងតាំង ឯកឧត្តម សូ គឹមអាន ជាអគ្គលេខាធិការរងនៃរាជរដ្ឋាភិបាលកម្ពុជា មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារដែលមានបច្ចុប្បន្ន ។

**មាត្រា ២ .-** នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ឱ្យបានសម្រេច ។

**មាត្រា ៣ .-** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ២២ ខែ មិនា ឆ្នាំ ២០០០

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

**ជា ស៊ីម**

★★★

# ព្រះរាជក្រឹត្យ ជស/រកត/០៣០០/១៣៨

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ រាជហរិវង្ស

ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

***

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ ព្រះរាជក្រម លេខ នស/រកម/៩៤/០២ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើត ក្រសួងការពារជាតិ

-បានទ្រង់យល់អនុក្រឹត្យលេខ ៣៧/អនក្រ/គត ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ១៩៩៩ ស្តីពីការកែសំរួលរចនាសម្ព័ន្ធចាត់តាំង នៃ ក្រសួងការពារជាតិ

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០១៩៩/២១ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ ១៩៩៩ ស្តីពីការកែសំរួលតួនាទីភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំង អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ

-យោងតាមសំណើ របស់សហរដ្ឋមន្ត្រី ក្រសួងការពារជាតិ និងនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ .-** ត្រូវបានតែងតាំងមុខងារ និង តម្លើងឋានន្តរសក្តិ ជូននាយទាហានជាន់ខ្ពស់ កងយោធពលខេមរភូមិន្ទ នៃអគ្គបញ្ជាការដ្ឋាន នៃក្រសួងការពារជាតិ ដូចមានរាយនាមខាងក្រោម ៖

**ក-តម្លើងឋានន្តរសក្តិ ថ្នាក់ឧត្តមសេនីយ៍ទោ :**

-ឧត្តមសេនីយ៍ត្រី **ខាំ ចាន់** អត្តលេខ ០០០១១៩ មេបញ្ជាការរងយោធភូមិភាគទី១ បច្ចុប្បន្ន ជាទីប្រឹក្សាក្រសួងការពារជាតិ

**ខ-តែងតាំងផ្លាស់ប្តូរមុខងារ :**

១-ឧត្តមសេនីយ៍ត្រី **សុខ ផល** អត្តលេខ ០០០១៩២ មេបញ្ជាការរងយោធភូមិភាគទី ៣ បច្ចុប្បន្ន ជានាយករងទីចាត់ការហិរញ្ញវត្ថុ អគ្គបញ្ជាការដ្ឋាន

២-ឧត្តមសេនីយ៍ត្រី **សេង សារី** អត្តលេខ ០០០០៩៨ មេបញ្ជាការរងយោធភូមិភាគទី ២

បច្ចុប្បន្ន ជានាយការិយាល័យការពារព្រំដែន
កងទ័ពជើងគោក

៣-ឧត្តមសេនីយ៍ត្រី ចាន់ ង៉ា អត្តលេខ ០០០៣៥១ នាយសេនាធិការដ្ឋាន កងអន្តរាគមន៍
បច្ចុប្បន្នជា មេបញ្ជាការរងយោធភូមិភាគទី ២

មាត្រា ២ .- នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ .- ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០០០

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្ថលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី
ហត្ថលេខា
ហ៊ុន សែន

ក្នុងព្រះបរមនាម និងតាមព្រះរាជបញ្ជាក់បង្គាប់
ប្រមុខរដ្ឋស្តីទី
ហត្ថលេខា
ជា ស៊ីម

បានជំរាបជូន
សម្តេចនាយករដ្ឋមន្ត្រី
ព្រះហស្តលេខា និងហត្ថលេខា
**ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ សិរីរត្ន ទៀ បាញ់**

★★★

# II- រាជរដ្ឋាភិបាល

## ១-អនុក្រឹត្យ

**អនុក្រឹត្យ លេខ ១១ អនក្រ.បក**

**ស្តីពី**

**នីតិវិធី នៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី**

***

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញក្រឹត្យលេខ១០០ក្រ ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ១៩៩២ ដែលប្រកាសអោយប្រើច្បាប់ភូមិបាល

-បានឃើញព្រះរាជក្រមលេខ ០៤/នស/៩៤ ចុះថ្ងៃទី១០ ខែ សីហា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

-បានឃើញអនុក្រឹត្យលេខ ២០ អនក្រ/បក ចុះថ្ងៃទី៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន

-បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ/បក ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

-បានការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងកិច្ចប្រជុំពេញអង្គ នាថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ ២០០០

## សំរេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១ .-**

អនុក្រឹត្យនេះកំណត់នីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លីតាមរបៀបការវិនិច្ឆ័យ ដែលមានលក្ខណៈជាប្រព័ន្ធនៅក្នុងតំបន់ដែលបានប្រកាសថាជាទីតាំងធ្វើការវិនិច្ឆ័យ ដូចមានចែងក្នុងមាត្រា២ នៃអនុក្រឹត្យនេះ ។

**មាត្រា ២ .-**

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវកំណត់និងណែនាំបច្ចេកទេសជំនាញ និង ទំរង់បែបបទនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី ដល់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត-ក្រុង ។

អភិបាលខេត្ត-ក្រុង ត្រូវចេញសេចក្តីប្រកាសកំណត់តំបន់ និងព្រំប្រទល់នៃទីតាំងធ្វើការវិនិច្ឆ័យតាមរបៀបបង្ហាញលើផែនទី ឬតាមរបៀបពិពណ៌នា ឬតាមរបៀបទាំងពីរ ។

## ជំពូកទី ២

## សមត្ថកិច្ច និង ភារកិច្ច

**មាត្រា ៣ .-**

នៅពេលដែលតំបន់ត្រូវធ្វើការវិនិច្ឆ័យបានប្រកាសហើយ អភិបាលខេត្ត-ក្រុងនៃតំបន់ ធ្វើការវិនិច្ឆ័យត្រូវតែងតាំងគណៈកម្មការ រដ្ឋបាលសំរាប់តំបន់ដែលត្រូវធ្វើការវិនិច្ឆ័យនោះ ។

សមាសភាពនៃគណៈកម្មការរដ្ឋបាលមាន :

| | |
|---|---|
| -តំណាង អភិបាលខេត្ត-ក្រុង | ជាប្រធាន |
| -មន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យ ជាមន្ត្រីសុរិយោដី | ជាសមាជិក |
| -អភិបាលស្រុក ខ័ណ្ឌ ឬ តំណាង | ជាសមាជិក |
| -មេឃុំ ចៅសង្កាត់ ឬ តំណាង | ជាសមាជិក |
| -មេភូមិ ឬ តំណាង | ជាសមាជិក |
| -ចាស់ព្រឹទ្ធាចារ្យក្នុងទីតាំងធ្វើការវិនិច្ឆ័យ ២រូប | ជាសមាជិក |

ភារកិច្ចរបស់គណៈកម្មការរដ្ឋបាលមាន :

-បិទផ្សាយជាសាធារណៈនូវប្លង់បញ្ជីសុរិយោដី ជាអាទិ៍ ប្លង់សុរិយោដី និងបញ្ជីឈ្មោះអ្នកកាន់កាប់ដី
-ទទួលពាក្យបណ្តឹងតវ៉ា ធ្វើការស្រាវជ្រាវ និងដោះស្រាយតាមការព្រមព្រៀង
-ធ្វើសេចក្តីសន្និដ្ឋានផ្តល់យោបល់លើឯកសារនៃការវិនិច្ឆ័យ
-លើកសំណើផ្តល់សិទ្ធិលើដីជូនអ្នកកាន់កាប់ ជូនកម្មសិទ្ធិករ ឬរក្សាទុកជាទ្រព្យសម្បត្តិរដ្ឋ ។

មាត្រា ៤ .-

នៅពេលដែលតំបន់ធ្វើការវិនិច្ឆ័យត្រូវបានកំណត់ហើយ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ត្រូវចាត់តាំងមន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យ ព្រមទាំងមន្ត្រីចាំបាច់មួយ ចំនួនទៀត រួមមាន : មន្ត្រីកំណត់ព្រំដី មន្ត្រីវិនិច្ឆ័យ និង មន្ត្រីវាស់វែង ដែលត្រូវបំពេញភារកិច្ចក្នុងតំបន់ធ្វើការវិនិច្ឆ័យ ។

មន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យដែលបានទទួលសេចក្តីណែនាំពីក្រសួង រៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវទទួលខុសត្រូវចំពោះការវិនិច្ឆ័យ ដែលបានកំណត់ក្នុងអនុក្រឹត្យនេះ ។ មន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យ មានសិទ្ធិដឹកនាំចេញសេចក្តីណែនាំចាំបាច់ដល់មន្ត្រីជំនាញ ដែលបានតែងតាំងក្នុងវាក្យខ័ណ្ឌទី១ មាត្រា៤ នៃអនុក្រឹត្យនេះ ។

មន្ត្រីកំណត់ព្រំដី មានសិទ្ធិចូលក្នុងបរិវេណអចលនវត្ថុណាមួយ នៅក្នុងតំបន់ធ្វើការវិនិច្ឆ័យ ដើម្បីកំណត់ព្រំនិងវាស់វែង ហើយអាចអញ្ជើញជនដែលពាក់ព័ន្ធអោយផ្តល់នូវចម្លើយដោយផ្ទាល់មាត់ ឯកសារ ឬ វត្ថុតាងផ្សេងៗ ទាក់ទងទៅនឹងព្រំនៃក្បាលដីណាមួយ ។ មន្ត្រីកំណត់ព្រំដីអាចអនុវត្តការងារតាមសិទ្ធិអំណាចផ្សេងទៀត ដែលផ្តល់ដល់មន្ត្រីវាស់វែងសុរិយោដី ដូចដែលមានចែងក្នុងច្បាប់ភូមិបាល ក្នុងកិច្ចការវាស់វែងដីធ្លី ។

មន្ត្រីវិនិច្ឆ័យមានសិទ្ធិសាកសួរយកពត៌មានចាំបាច់សំរាប់អនុវត្តការងារវិនិច្ឆ័យ អាចអញ្ជើញជនដែលពាក់ព័ន្ធអោយផ្តល់នូវចម្លើយដោយផ្ទាល់មាត់ ឯកសារ ឬ វត្ថុតាងផ្សេងៗ ទាក់ទងទៅនឹងការវិនិច្ឆ័យ ។

មាត្រា ៥ .-

ក្នុងតំបន់ធ្វើការវិនិច្ឆ័យ ជនដែលមានការពាក់ព័ន្ធ មានកាតព្វកិច្ចចូលរួម និងសហការក្នុងការកំណត់ព្រំដី និងការវិនិច្ឆ័យដោយផ្តល់នូវចម្លើយដោយផ្ទាល់មាត់ ឬ ជាលាយលក្ខណ៍អក្សរ ឯកសារ ឬ វត្ថុតាងផ្សេងៗ ដល់មន្ត្រីជំនាញ ដើម្បីអនុវត្តការកំណត់ព្រំដី ការវាស់វែង និងការវិនិច្ឆ័យ ។

ជនគ្រប់រូបមានសិទ្ធិចូលរួមពិនិត្យ និងផ្តល់យោបល់ ក្នុងរយៈពេលនៃការបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យ និងមានសិទ្ធិសុំអោយមន្ត្រីជំនាញពន្យល់បំភ្លឺអំពីខ្លឹមសារនៃឯកសារ ដែលពាក់ព័ន្ធនឹងតំបន់ធ្វើការវិនិច្ឆ័យ ។

**មាត្រា ៦ .-**

អភិបាលខេត្ត-ក្រុង ត្រូវធ្វើលិខិតផ្លូវការដែលពិពណ៌នា និងអនុញ្ញាតអោយអនុវត្តនីតិវិធីវិនិច្ឆ័យ ដែលមានលក្ខណៈជាប្រព័ន្ធទៅអាជ្ញាធរមូលដ្ឋាននៃតំបន់ធ្វើការវិនិច្ឆ័យ យ៉ាងយោចណាស់១៥ថ្ងៃ មុនកិច្ចប្រជុំផ្សព្វផ្សាយសេចក្តីប្រកាសកំណត់តំបន់ធ្វើការវិនិច្ឆ័យ ។

អភិបាលខេត្ត-ក្រុង ត្រូវជូនដំណឹងជាសាធារណៈអំពីពេលវេលា និងទីកន្លែងនៃកិច្ចប្រជុំផ្សព្វផ្សាយ ។ សេចក្តីជូនដំណឹង ត្រូវបិទអោយសាធារណជនដឹងយ៉ាងយោចណាស់ ៧ថ្ងៃ មុនបើកកិច្ចប្រជុំផ្សព្វផ្សាយក្នុងកន្លែងដែលងាយមើលឃើញនៅក្នុងភូមិ ឬ នៅទីតាំងធ្វើការវិនិច្ឆ័យផ្ទាល់ ។ សេចក្តីប្រកាសត្រូវតែផ្សព្វផ្សាយអោយបានទូលំទូលាយ និងមានប្រសិទ្ធភាពក្នុងទីតាំងធ្វើការវិនិច្ឆ័យ ដោយសហការជាមួយអាជ្ញាធរមូលដ្ឋាន ។

កិច្ចប្រជុំផ្សព្វផ្សាយសេចក្តីប្រកាសកំណត់តំបន់ធ្វើការវិនិច្ឆ័យដែលមានលក្ខណៈជាប្រព័ន្ធ ត្រូវរៀបចំធ្វើនៅក្នុងទីតាំងធ្វើការវិនិច្ឆ័យ ។ ក្នុងកិច្ចប្រជុំនោះ មន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យ ឬតំណាងគណៈកម្មការរដ្ឋបាល ត្រូវពន្យល់ពីដំណើរការនៃការវិនិច្ឆ័យ បំភ្លឺពីបញ្ហាច្បាប់ និងឆ្លើយរាល់សំណួរទាក់ទងនឹងការវិនិច្ឆ័យដែលបានលើកឡើង ។

កិច្ចប្រជុំបន្ថែមសំរាប់ថ្នាក់ភូមិ នឹងត្រូវបានរៀបចំ ប្រសិនបើមន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យ ឬ អាជ្ញាធរមូលដ្ឋានចាត់ទុកថាជាការចាំបាច់ ។

**មាត្រា ៧ .-**

មន្ត្រីកំណត់ព្រំដីត្រូវជូនដំណឹងដល់ថ្នាក់ដឹកនាំមូលដ្ឋានអំពីការកំណត់ព្រំដីក្នុងតំបន់ធ្វើការវិនិច្ឆ័យពេលវេលា និងទីកន្លែងដែលនឹងចាប់ផ្តើមធ្វើការវិនិច្ឆ័យ អោយបានមុន ៧ថ្ងៃយ៉ាងតិច ។ សេចក្តីជូនដំណឹង តម្រូវអោយជនដែលពាក់ព័ន្ធមកចង្អុលបង្ហាញព្រំប្រទល់នៃអចលនវត្ថុរបស់ខ្លួន តាមរបៀបដែលបានបញ្ជាក់ក្នុងសេចក្តីប្រកាសជូនដំណឹង ។

បន្ទាប់មក មន្ត្រីកំណត់ព្រំដីដែលបានទទួលការណែនាំពីអ្នកគ្រប់គ្រងការងារតំបន់វិនិច្ឆ័យ ត្រូវកំណត់ព្រំប្រទល់អចលនវត្ថុទាំងអស់ដែលបង្កើតបានជាក្បាលដីក្នុងប្លង់សុរិយោដី ។ ក្នុងរយៈពេលធ្វើការកំណត់ព្រំប្រទល់ក្បាលដី មន្ត្រីកំណត់ព្រំដីត្រូវគោរពគោលការណ៍ដូចខាងក្រោម :

ក-បើកម្មសិទ្ធិករ ឬ ម្ចាស់នៃក្បាលដី និងម្ចាស់នៃក្បាលដីដែលជាប់ព្រំ មានវត្តមាន ហើយព្រមព្រៀងលើព្រំប្រទល់ នោះព្រំប្រទល់នឹងត្រូវបានកំណត់យោងតាមការព្រមព្រៀង ។

ខ-បើការព្រមព្រៀងដែលរៀបរាប់ក្នុងចំណុច(ក) នៃមាត្រានេះមិនអាចធ្វើទៅបាន ឬមានកម្មសិទ្ធិករ ឬម្ចាស់នៃក្បាលដី និងម្ចាស់នៃក្បាលដីដែលនៅជាប់ព្រំណាមួយអវត្តមាន នោះព្រំប្រទល់ត្រូវកំណត់នៅលើដីតាមឯកសារដែលមាន និង ភស្តុតាងជាលក្ខណៈរូបធាតុឬជាលាយលក្ខណ៍អក្សរ ឬចម្លើយផ្ទាល់មាត់ទាក់ទងនឹងព្រំដី។

គ-ចំពោះក្បាលដីដែលមានព្រំប្រទល់ជាប់នឹងដីសាធារណៈ និងក្បាលដីដែលប្រើប្រាស់ជាសាធារណៈ ព្រំប្រទល់ក្បាលដី ត្រូវកំណត់ដោយអនុលោមទៅតាមចំណុច (ក) ឬ (ខ) នៃវាក្យខណ្ឌទី២ មាត្រា៧ នៃអនុក្រឹត្យនេះ ។

មាត្រា ៨ .-

មន្ត្រីវាស់វែងដែលបានទទួលការណែនាំពីមន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យ ត្រូវអនុវត្តការងារវាស់វែងដែលជាតម្រូវការក្នុងការប្រតិបត្តិនីតិវិធីវិនិច្ឆ័យ និងរៀបចំប្លង់សុរិយោដី ។

មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដីខេត្ត-ក្រុង ត្រូវណែនាំលំអិតអំពីទំរង់បែបបទ និងខ្នាតមាត្រា នៃប្លង់សុរិយោដី ។

## ជំពូកទី ៣
## នីតិវិធី នៃការវិនិច្ឆ័យ

មាត្រា ៩ .-

មន្ត្រីវិនិច្ឆ័យដែលបានទទួលការណែនាំពីមន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យ ត្រូវអង្កេតរាល់ឯកសារ ភស្តុតាង និងពត៌មានផ្សេងៗជាលាយលក្ខអក្សរ ឬ ផ្ទាល់មាត់ ទាក់ទងទៅនឹងសិទ្ធិលើក្បាលដីនីមួយៗ ក្នុងតំបន់ធ្វើការវិនិច្ឆ័យ ហើយកត់ត្រាសិទ្ធិទាំងនេះចូលក្នុងទំរង់បែបបទនៃការប្រមូលទិន្នន័យក្បាលដី ។

មាត្រា ១០ .-

ការរៀបចំឯកសារនៃការវិនិច្ឆ័យ មានន័យដូចខាងក្រោម :

១-ឯកសារនៃការវិនិច្ឆ័យត្រូវមាន :

-ប្លង់សុរិយោដី

-បញ្ជីឈ្មោះម្ចាស់ដី

-ទំរង់បែបបទនៃការប្រមូលទិន្នន័យក្បាលដី ។ ទំរង់បែបបទនៃការប្រមូលទិន្នន័យក្បាលដីនីមួយៗ ត្រូវបង្ហាញ :

ក-អត្តសញ្ញាណក្បាលដី

ខ-អត្តសញ្ញាណម្ចាស់ដី

គ-កាលបរិច្ឆេទនៃការវិនិច្ឆ័យ ។

២-ទំរង់បែបបទនៃការប្រមូលទិន្នន័យក្បាលដី ត្រូវផ្តិតមេដៃឬចុះហត្ថលេខាពីម្ចាស់ដី ព្រមទាំងអ្នកជាប់ព្រំ ហើយត្រូវចុះហត្ថលេខា ដោយមន្ត្រីវិនិច្ឆ័យ ។

៣-នៅពេលដែលឯកសារនៃការវិនិច្ឆ័យត្រូវបានបំពេញបរិបូរណ៍គ្រប់ហើយ មន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យ ត្រូវចុះហត្ថលេខាលើឯកសារទាំងនេះ ។

**មាត្រា ១១ .-**

ការបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យ ដែលរួមមាន ប្លង់សុរិយោដី និងបញ្ជីឈ្មោះម្ចាស់ដី ត្រូវមានរយៈពេល ៣០ថ្ងៃ នៅកន្លែងដែលងាយមើលឃើញសំរាប់ការអង្កេតជាសាធារណៈនៅក្នុងតំបន់ធ្វើការវិនិច្ឆ័យ ។

អាជ្ញាធរខេត្ត-ក្រុង ត្រូវផ្សព្វផ្សាយដំណឹងអំពីការបិទផ្សាយជាសាធារណៈ នូវឯកសារនៃការវិនិច្ឆ័យតាមសំណើររបស់គណៈកម្មការរដ្ឋបាល ។

ក្នុងរយៈពេលនៃការបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យ មន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យ អាចកែតំរូវការខុសឆ្គង ឬ ការភ្លេចភ្លាំងណាដែលមិនជះឥទ្ធិពលដល់ផលប្រយោជន៍ត្រឹមត្រូវស្របច្បាប់នៃជនណាមួយ ។ ការកែតម្រូវផ្សេងៗក្នុងឯកសារនៃការវិនិច្ឆ័យ អាចធ្វើបានលុះណាតែមានការយល់ព្រមពីជនពាក់ព័ន្ធ ដែលទទួលឥទ្ធិពលពីការកែតម្រូវនោះ ។

**មាត្រា ១២ .-**

ក្នុងអំឡុងពេលនៃការបិទផ្សាយជាសាធារណៈ ជនណាដែលមានឈ្មោះក្នុងបញ្ជី ឬ អ្នកដែលអាងផលប្រយោជន៍លើក្បាលដីណាមួយ ដែលបានចាត់ទុកថាឯកសារនៃការវិនិច្ឆ័យមិនជាក់លាក់ ឬមិនពេញលេញ អាចផ្តល់ដំណឹងដល់គណៈកម្មការរដ្ឋបាលនូវការជំទាស់របស់ខ្លួន ។

ក្រោយពីផ្តល់នូវការកត់សំគាល់ដ៏សមហេតុផលដល់ជនគ្រប់រូបដែលពាក់ព័ន្ធនឹងការជំទាស់ និង បន្ទាប់ពីពិគ្រោះជាមួយអ្នកដែលធ្វើការជំទាស់គណៈកម្មការរដ្ឋបាល ត្រូវព្យាយាមដោះស្រាយតាមការព្រមព្រៀង ។

ការជំទាស់ ឬ វិវាទណាមួយ ដែលមិនអាចដោះស្រាយបាន ត្រូវបញ្ជូនទៅតុលាការ ។ ក្នុងករណីនេះ : គណៈកម្មការរដ្ឋបាល ត្រូវអនុវត្តតាមសេចក្តីសំរេចចុងក្រោយរបស់តុលាការ ។

**មាត្រា ១៣ .-**

ក្រោយពីផុតកំណត់រយៈពេលនៃការបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យ និង បញ្ចប់ការដោះស្រាយទំនាស់តាមនីតិវិធី ដូចមានចែងក្នុងមាត្រា១២នៃអនុក្រឹត្យនេះ គណៈកម្មការរដ្ឋបាលត្រូវផ្តល់ការយល់ព្រមលើឯកសារ នៃការវិនិច្ឆ័យចំពោះក្បាលដីទាំងឡាយណាដែល មិនមានទំនាស់ ។

បន្ទាប់ពីការយល់ព្រម គណៈកម្មការរដ្ឋបាលត្រូវបញ្ជូនឯកសារនៃការវិនិច្ឆ័យទៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ដើម្បីពិនិត្យលើលក្ខណៈបច្ចេកទេស និង ចុះហត្ថលេខា ហើយបញ្ជូនទៅអភិបាលខេត្ត-ក្រុង ចុះហត្ថលេខា ។

**មាត្រា ១៤ .-**

ក្រោយពីអភិបាលខេត្ត-ក្រុង និងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ចុះហត្ថលេខា ហើយ ឯកសានៃការវិនិច្ឆ័យ ត្រូវបានបញ្ចប់ជាស្ថាពរចំពោះក្បាលដី ដែលមិនមានទំនាស់ ។ ចំពោះឯកសារនៃការវិនិច្ឆ័យដែលនៅពាក់ព័ន្ធនឹងវិវាទ នឹងត្រូវបញ្ចប់ជាស្ថាពរនៅពេលមានសេចក្តីសំរេចពីតុលាការដូចដែលបានចែងក្នុងមាត្រា១២ នៃអនុក្រឹត្យនេះ ។

នៅពេលដែលឯកសារនៃការវិនិច្ឆ័យត្រូវបានបញ្ចប់ជាស្ថាពរបែបផែនតាមវាក្យខ័ណ្ឌទី១នៃមាត្រានេះឯកសារនៃការវិនិច្ឆ័យព្រមទាំងឯកសារទាំងអស់ដែលទទួលបានក្នុងអំឡុងពេលនៃការវិនិច្ឆ័យ ដែលមានលក្ខណៈជាប្រព័ន្ធ ត្រូវបញ្ជូនទៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្ត-ក្រុង តាមលំដាប់ថ្នាក់ដើម្បីចុះបញ្ជី ។

ក្រោយពេលក្បាលដីដែលមានក្នុងឯកសារនៃការវិនិច្ឆ័យត្រូវបានចុះបញ្ជីហើយ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវចេញវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុ ឬ ប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលើគ្រប់ក្បាលដីក្នុងតំបន់ ធ្វើការវិនិច្ឆ័យនេះ ។ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អាចប្រគល់សិទ្ធិអោយខេត្ត-ក្រុងណាដែលមានគ្រប់លក្ខណៈសម្បត្តិ ដើម្បីចេញវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុ ឬ ប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុនេះ នៅក្នុងតំបន់ធ្វើការវិនិច្ឆ័យនៃខេត្ត-ក្រុង របស់ខ្លួន ។

## ជំពូកទី៥

## អវសានប្បញ្ញត្តិ

**មាត្រា ១៥ .-**

អនុក្រឹត្យនេះ មានអានុភាពលើតំបន់ដែលបានដំណើរការធ្វើការវិនិច្ឆ័យ មានលក្ខណៈជាប្រព័ន្ធកន្លងមក។

**មាត្រា ១៦ .-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ១៧ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រី រដ្ឋលេខាធិការ និងអភិបាលខេត្ត-ក្រុង ទាំងអស់ដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០០០

បានជំរាបជូន<br>សម្តេចនាយករដ្ឋមន្ត្រី<br>រដ្ឋមន្ត្រី ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់<br>ហត្ថលេខា<br>**អ៊ឹម ឈុនលឹម**

នាយករដ្ឋមន្ត្រី<br>ហត្ថលេខា និងត្រា<br>**ហ៊ុន សែន**

★★★

## វិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុ

**លេខ : 00000001 អ.សក**

***

ខេត្ត តាកែវ លេខកូដ ២១០៧០៨០១

ស្រុក-ខ័ណ្ឌ ស្រុកសំរោង លេខក្បាលដី ៣០

ឃុំ - សង្កាត់ ជំរះពេន ទំហំ ១៥៨៧ ម²

ភូមិ ស្រែតាសុក

ឈ្មោះកម្មសិទ្ធិករ **គីម គឿន** និងនាង **ឡុង មិន**

(ប្តី-ប្រពន្ធ)

អាស័យដ្ឋាន ភូមិស្រែតាសុក ឃុំជំរះពេន ស្រុកសំរោង ខេត្តតាកែវ

ប្រភពនៃការផ្តល់ដី រដ្ឋចែកអោយ

បន្ទុក គ្មាន







ធ្វើនៅភ្នំពេញ,ថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០០០

**អគ្គនាយកសុរិយោដី និង ភូមិសាស្ត្រ**

មាត្រាដ្ឋាន ១/ ២០០០

យោងតាមអនុក្រឹត្យ ១១ អនក្រ.បក ចុះថ្ងៃទី ២២ ខែមីនា ឆ្នាំ ២០០០

**ប្រកាស** : បើលោកអ្នកបានទទួលវិញ្ញាប័ត្រសំគាល់ម្ចាស់អចលនវត្ថុនេះ ដោយបានចំណែកជាកេរ្តិ៍ ទទួលទិញ-ដូរក្តី ឬទទួលបញ្ចាំក្តីឬលោកអ្នក ក៏ឲ្យនាំម្ចាស់ដីទៅធ្វើលិខិតជាលាយលក្ខណ៍អក្សរនៅចំពោះមុខមន្ត្រីមានសមត្ថកិច្ច និងផ្លាស់ឈ្មោះនៅការិយាល័យ រៀបចំដែនដីនគររូបនីយកម្ម សំណង់ និងភូមិបាលស្រុកដែលដីធ្លីលោកអ្នកស្ថិតនៅ ព្រោះ បើកាលណាមិនបានបំពេញកិច្ចទាំង នេះទេ អចលនវត្ថុនោះនឹងទុកជាធានាប្រាក់លោកអ្នកក៏មិនកើត ឬទុកជាកម្មសិទ្ធិរបស់លោកអ្នកក៏ពុំបាន ។

***

## អនុក្រឹត្យ លេខ ១២ អនក្រ.បក

### ស្តីអំពីការបង្កើតរចនាសម្ព័ន្ធ នៃក្រុមប្រឹក្សាសំរាយកងកំលាំងប្រដាប់អាវុធ

***

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៧២ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ

-បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ បក ចុះថ្ងៃទី១២ ខែ ឧសភា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតក្រុមប្រឹក្សារំសាយកងកំលាំងប្រដាប់អាវុធ

-បានឃើញអនុក្រឹត្យលេខ ៤២ អនក្រ បក ចុះថ្ងៃទី១២ ខែ ឧសភា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតអគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សារំសាយកងកំលាំងប្រដាប់អាវុធ

-យោងសេចក្តីជូនដំណឹងលេខ ២០៩ សជណគរ ចុះថ្ងៃទី០៩ ខែ កុម្ភៈ ឆ្នាំ ២០០០ ស្តីពីលទ្ធផលនៃសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នាថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ២០០០

-យោងតាមតំរូវការភារកិច្ចចាំបាច់ និង តាមសំណើរបស់ប្រធានក្រុមប្រឹក្សារំសាយកងកំលាំងប្រដាប់អាវុធ

**សំរេច**

**ជំពូក ១**

**រចនាសម្ព័ន្ធ នៃក្រុមប្រឹក្សារំសាយកងកំលាំងប្រដាប់អាវុធ**

**មាត្រា ១.-**

ត្រូវបានបង្កើតរចនាសម្ព័ន្ធ ០៤នាយកដ្ឋាន និង០១ មជ្ឈមណ្ឌលកុំព្យូទ័រ ចំណុះអោយអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សារំសាយកងកំលាំងប្រដាប់អាវុធ សំរាប់អនុវត្តកម្មវិធីរំសាយទ័ព រួមមាននាយកដ្ឋានដូចខាងក្រោម :

១-នាយកដ្ឋាន បុគ្គលិក និងរដ្ឋបាល

**២-នាយកដ្ឋាន ប្រតិបត្តិការ និង ភស្តុភារ**

**៣-នាយកដ្ឋាន ហិរញ្ញវត្ថុ**

**៤-នាយកដ្ឋាន សមាហរណកម្ម**

**៥-មជ្ឈមណ្ឌលកុំព្យូទ័រ**

## ជំពូក ២

## នាយកដ្ឋាន បុគ្គលិក និង រដ្ឋបាល

**មាត្រា ២ .-**

នាយកដ្ឋានបុគ្គលិក និងរដ្ឋបាល ធ្វើជាសេនាធិការអោយអគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សា រំសាយកងកំលាំងប្រដាប់អាវុធ លើការងារ :

- គ្រប់គ្រងរដ្ឋបាល និងបុគ្គលិករបស់អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សារំសាយកងកំលាំងប្រដាប់អាវុធ ។
- រៀបចំលិខិតបទដ្ឋានសំរាប់ការគ្រប់គ្រងការងារ ក្នុងអគ្គលេខាធិការដ្ឋាន ។
- ធ្វើការវាយតំលៃតំរូវការ ការងារបណ្តុះបណ្តាលធនធានមនុស្សរបស់អគ្គលេខាធិការដ្ឋាន ។
- សំរបសំរួលការងារគ្រប់ផ្នែករបស់អគ្គលេខាធិការដ្ឋាន ជាមួយក្រសួង និង ស្ថាប័នពាក់ព័ន្ធ ចាប់ពីថ្នាក់លើរហូតដល់មូលដ្ឋាន ។
- គ្រប់គ្រង និងចរាចរឯកសាររដ្ឋបាលរបស់អគ្គលេខាធិការដ្ឋាន ដើម្បីធានាបានប្រសិទ្ធភាព និងសុវត្ថិភាពរដ្ឋបាល ។

## ជំពូក ៣

## នាយកដ្ឋាន ប្រតិបត្តិការ និងភស្តុភារ

**មាត្រា ៣ .-**

នាយកដ្ឋានប្រតិបត្តិការ និង ភស្តុភារ ធ្វើជាសេនាធិការអោយអគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សារំសាយកងកំលាំងប្រដាប់អាវុធ លើការងារ :

- សហការជាមួយក្រសួងការពារជាតិ អគ្គសេនាធិការដ្ឋាន គណៈកម្មការរំសាយទ័ពក្នុងកងយោធពលខេមរភូមិន្ទ ដើម្បីរៀបចំផែនការ ការកំណត់ចំនួនយោធិនដែលត្រូវរំសាយ ស្រង់បញ្ជីឈ្មោះទាហានរំសាយ និងធ្វើផែនការសំរាប់អនុវត្តការងាររំសាយជាក់ស្តែង តាមដំណាក់កាលនីមួយៗ ។
- សហការជាមួយគណៈកម្មការរំសាយទ័ពក្នុងកងយោធពលខេមរភូមិន្ទ ដើម្បីកំណត់ចំនួនមណ្ឌលប្រមូលផ្តុំសំរាប់រំសាយទ័ពតាមដំណាក់កាលនីមួយៗ និងរៀបចំផែនការដឹកជញ្ជូនយោធិនរំសាយពីមណ្ឌលប្រមូលផ្តុំទៅកាន់មូលដ្ឋាន ព្រមទាំងរៀបចំក្រុមការពារសុវត្ថិភាព សណ្តាប់ធ្នាប់ក្នុងមណ្ឌល និងជុំវិញបណ្តុំប្រមូលផ្តុំតាមដំណាក់កាលនីមួយៗ ។
- សហការជាមួយគណៈកម្មការរំសាយទ័ព ជំនាញការបច្ចេកទេសចុះសិក្សាស្រាវជ្រាវអំពីជីវភាពរស់នៅរបស់យោធិនដែលត្រូវរំសាយ ដើម្បីរៀបចំកម្មវិធីជំនួយឧបត្ថម្ភជាក់ស្តែង ។
- លើកគំរោងផែនការតម្រូវការសំភារៈ សំរាប់អនុវត្តកម្មវិធីរំសាយទ័ព និងជំនួយឧបត្ថម្ភអតីតយុទ្ធជនកម្ពុជា ។
- រៀបចំបណ្តុះបណ្តាលសមាជិកក្រុមបច្ចេកទេសសំរាប់អនុវត្តកម្មវិធីរំសាយទ័ព ។

## ជំពូក ៤
## នាយកដ្ឋានហិរញ្ញវត្ថុ

មាត្រា ៤ .-

នាយកដ្ឋានហិរញ្ញវត្ថុ ធ្វើជាសេនាធិការអោយអគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាសោធកងកំលាំងប្រដាប់អាវុធ លើការងារដូចខាងក្រោម :

- សហការជាមួយក្រុមជំនាញការបច្ចេកទេស និងគ្រប់នាយកដ្ឋានរបស់អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាសោធកងកំលាំងប្រដាប់អាវុធ ដើម្បីលើកគំរោងថវិកាសំរាប់រៀបចំអនុវត្តកម្មវិធីសោធយុទ្ធ ។
- លើកគំរោងតម្រូវការថវិកាចំណូល-ចំណាយរបស់អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាសោធកងកំលាំងប្រដាប់អាវុធ ដើម្បីអនុវត្តការងារតាមដំណាក់កាលនីមួយៗ ។
- ប្រមូលផ្តុំ និងធ្វើការសំរបសំរួលលើការប្រើប្រាស់ថវិកា ។
- ប្រមូលផ្តុំ និងសំរបសំរួលលើការចំណាយផ្សេងៗរបស់អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាសោធកងកំលាំងប្រដាប់អាវុធ ។
- គ្រប់គ្រងគណនីពិសេស និងគណនីបដិភាគរបស់រាជរដ្ឋាភិបាល ក្នុងការអនុវត្តន៏កម្មវិធីជំនួយឧបត្ថម្ភ យោធិនរំសាយតាមដំណាក់កាលនីមួយៗ ។
- បូកសរុបរបាយការចំណូល-ចំណាយដើម្បីរាយការណ៍ជូនអគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សារំសាយកងកំលាំងប្រដាប់អាវុធ តាមការណែនាំជាក់ស្តែង ។
- រៀបចំ និងចុះបញ្ជីគណនេយ្យនូវរាល់ប្រតិបត្តិការចំណាយជាប្រចាំ ព្រមទាំងរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ស្តីពីការអនុវត្តន៏គំរោងតាមដំណាក់កាលនីមួយៗ ។

## ជំពូក ៥
## នាយកដ្ឋានសមាហរណកម្ម

មាត្រា ៥ .-

នាយកដ្ឋានសមាហរណកម្មធ្វើជាសេនាធិការអោយអគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សារំសាយកងកំលាំងប្រដាប់អាវុធ លើការងារដូចខាងក្រោម :

- សហការជាមួយគណៈកម្មការរំសាយទ័ពក្នុងកងយោធពលខេមរភូមិន្ទ រៀបចំចងក្រងឯកសារសំរាប់ធ្វើការអប់រំ និងធ្វើការផ្សព្វផ្សាយដល់យោធិនរំសាយក្នុងមណ្ឌលប្រមូលផ្តុំ ។
- បូកសរុបចំនួនយោធិនរំសាយ និងចំនួនទាហានរំសាយតាមមណ្ឌល ដែលទៅរស់នៅតាមមូលដ្ឋាននីមួយៗ ។
- សហការជាមួយគណៈកម្មការអតីតយុទ្ធជនខេត្ត គណៈកម្មការអភិវឌ្ឍន៏ខេត្ត អង្គការអន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាល ដើម្បីរៀបចំការអភិវឌ្ឍន៏ក្នុងសហគមន៏ ដែលអតីតយុទ្ធជនទៅរស់នៅ ។

- បូកសរុបលទ្ធផលការងារដែលបានអនុវត្ត ដើម្បីរាយការណ៍ជូនអគ្គលេខាធិការដ្ឋាន ។

## ជំពូក ៦

## មជ្ឈមណ្ឌល កុំព្យូទ័រ

មាត្រា ៦ .-

មជ្ឈមណ្ឌលកុំព្យូទ័រ ធ្វើជាសេនាធិការអោយអគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាសំរាបសំរួលការងារកងកំលាំងប្រដាប់អាវុធ លើការងារដូចខាងក្រោម :

- រៀបចំប្រព័ន្ធកុំព្យូទ័រ និងគ្រប់គ្រងកម្មវិធីកុំព្យូទ័រ សំរាប់បញ្ចូលប្រវត្តិរូបយោធិន ។
- បង្កើតតារាងបើកប្រាក់បៀវត្សរ៍របស់កងយោធពលខេមរភូមិន្ទតាមប្រព័ន្ធកុំព្យូទ័រ និងវិភាគទិន្នន័យដែល បានបញ្ចូលក្នុងប្រព័ន្ធកុំព្យូទ័រ សំរាប់បំរើអោយការងារសំរាយទ័ព ។
- ធានាសុវត្ថិភាពប្រព័ន្ធបច្ចេកទេស និងទិន្នន័យដែលបានបញ្ចូលក្នុងប្រព័ន្ធកុំព្យូទ័រ ។
- រៀបចំកម្មវិធីជាប្រចាំ ដើម្បីបណ្តុះបណ្តាលបុគ្គលិកកុំព្យូទ័រអោយមានសមត្ថភាពគ្រប់គ្រាន់សំរាប់បំរើអោយការងារសំរាយទ័ព ។

## ជំពូក ៧

## អវសានប្បញ្ញត្តិ

មាត្រា ៧ .-

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៨ .-

អនុក្រឹត្យនេះមានឥទ្ធិពលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

មាត្រា ៩ .-

ឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ក្រុមប្រឹក្សាសំរាបសំរួលការងារកងកំលាំងប្រដាប់អាវុធ គណៈកម្មការសំរាយទ័ពក្នុងកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ។

រាជធានីភ្នំពេញ,ថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★


ក្រុមប្រឹក្សារំសាយកងកំលាំងប្រដាប់អាវុធ
អគ្គលេខាធិការ
នាយកដ្ឋានហិរញ្ញវត្ថុ
អគ្គលេខាធិការរង
អគ្គលេខាធិការរង
អគ្គលេខាធិការរង
នាយកដ្ឋាន រដ្ឋបាល និងបុគ្គលិក
នាយកដ្ឋានប្រតិបត្តិការ និងភស្តុភារ
នាយកដ្ឋាន សមាហរណកម្ម
មជ្ឈមណ្ឌល កុំព្យូទ័រ

# អនុក្រឹត្យលេខ ១៣ អនក្រ.បក
## ស្តីពី
## ការបង្កើតគណៈកម្មការ អតីតយុទ្ធជនខេត្ត

***

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៧២ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ

-បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ បក ចុះថ្ងៃទី១២ ខែ ឧសភា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកងកំលាំងប្រដាប់អាវុធ

-បានឃើញអនុក្រឹត្យលេខ ៥២ អនក្រ បក ចុះថ្ងៃទី១២ ខែ ឧសភា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតអគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកងកំលាំងប្រដាប់អាវុធ

-យោងសេចក្តីជូនដំណឹងលេខ ២០៩ សជណ.គស ចុះថ្ងៃទី០៩ ខែ កុម្ភៈ ឆ្នាំ ២០០០ ស្តីពី[illegible]នៃសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នាថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ២០០០

-តាមសំណើរបស់ប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកងកំលាំង ប្រដាប់អាវុធ

## សំរេច

## គណៈកម្មការអតីតយុទ្ធជនខេត្ត

**មាត្រា ១ .-** ត្រូវបានបង្កើតគណៈកម្មការអតីតយុទ្ធជនចំនួន ០៤ខេត្ត សំរាប់ដំណើរការអនុវត្តន៍កម្មវិធីសាកល្បង ។

គណៈកម្មការអតីតយុទ្ធជនខេត្តនេះ មានបេសកកម្មអនុលោមទៅតាមការតម្រង់ទិស និងស្ថិតក្រោមការត្រួតពិនិត្យដោយផ្ទាល់របស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកងកំលាំងប្រដាប់អាវុធ ។ ចំនួនខេត្តដែលត្រូវបង្កើតគណៈកម្មការអតីតយុទ្ធជនខេត្តនេះ រួមមាន :

១-ខេត្ត កំពត

២-ខេត្ត កំពង់ធំ

៣-ខេត្ត បាត់ដំបង

៤-ខេត្ត បន្ទាយមានជ័យ

**មាត្រា ២ .–** គណៈកម្មការអតីតយុទ្ធជនខេត្ត មានសមាសភាពដូចតទៅ :

| | |
|---|---|
| ១- អភិបាលខេត្ត | ជាប្រធាន |
| ២- ប្រធានមន្ទីរអភិវឌ្ឍន៍ជនបទ | ជាអនុប្រធាន |
| ៣- ប្រធានមន្ទីរកិច្ចការនារី និង អតីតយុទ្ធជន | ជាសមាជិក |
| ៤- ប្រធានមន្ទីរសង្គមកិច្ចការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា | ជាសមាជិក |
| ៥- ប្រធានប្រធានមន្ទីររៀបចំដែនដី និងនគរូបនីយកម្ម និងសំណង់ | ជាសមាជិក |
| ៦- ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ជាសមាជិក |
| ៧- ប្រធានមន្ទីរអប់រំ យុវជន និងកីឡា | ជាសមាជិក |
| ៨- ប្រធានមន្ទីរសុខាភិបាល | ជាសមាជិក |
| ៩- មេបញ្ជាការតំបន់ប្រតិបត្តិការសឹករងខេត្ត | ជាសមាជិក |
| ១០- ស្នងការនគរបាលខេត្ត | ជាសមាជិក |

**មាត្រា ៣ .–** គណៈកម្មការអតីតយុទ្ធជនខេត្ត មានសិទ្ធិបង្កើតលេខាធិការដ្ឋានប្រតិបត្តិការមួយធ្វើជា សេនាធិការផ្ទាល់ ។

**មាត្រា ៤ .–** ដើម្បីប្រតិបត្តិតាមគោលការណ៍ដូចមានចែងក្នុងមាត្រា ០១ខាងលើ គណៈកម្មការអតីតយុទ្ធជនខេត្ត មានភារកិច្ចសហការជាមួយអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សារំសាយកងកំលាំងប្រដាប់អាវុធដើម្បីអនុវត្ត និងត្រួតពិនិត្យមើលលើការងារមុនពេល និងក្នុងពេលរំសាយ ការងារផ្តល់ឧបត្ថម្ភក្នុងអន្តរកាល ការងារសមាហរណកម្ម និង ការងារអភិវឌ្ឍន៍សហគមន៍ ដូចខាងក្រោមនេះ :

**ក-ការងារមុនពេលរំសាយ**

- សហការជាមួយអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សារំសាយកងកំលាំងប្រដាប់អាវុធ ដើម្បីកំណត់ចំនួនយោធិនរំសាយតាមមុខសញ្ញាជាក់ស្តែងដែលត្រូវទៅរស់នៅតាមមូលដ្ឋាន និង ត្រៀមលក្ខណៈរៀបចំភូមិសាស្ត្រសំរាប់ទទួលយោធិនរំសាយដែលទៅតាំងទីលំនៅ ។
- សហការជាមួយអគ្គលេខាធិការដ្ឋាន ដើម្បីធ្វើការបណ្តុះបណ្តាលមន្ត្រីរបស់គណៈកម្មការអតីតយុទ្ធជនខេត្ត និងលេខាធិការដ្ឋានប្រតិបត្តិលើការងារត្រៀមរៀបចំសំរាប់បំពេញការងាររំសាយទ័ព ។
- រៀបចំ និងកំណត់ភារកិច្ចលេខាធិការដ្ឋានប្រតិបត្តិ ដើម្បីគ្រប់គ្រងតំបន់ និងតាមដានគ្រប់សកម្មភាពរបស់យោធិនរំសាយដែលទៅរស់នៅតាមមូលដ្ឋាន ។

**ខ-ការងារពេលរំសាយ**

- សហការជាមួយអគ្គលេខាធិការដ្ឋាន ត្រូវចុះបញ្ជីឈ្មោះយោធិនរំសាយ ក្នុងមណ្ឌលប្រមូលផ្តុំដែលត្រូវទៅរស់នៅតាមមូលដ្ឋាន ។

- សហការជាមួយអគ្គលេខាធិការដ្ឋានដឹកជញ្ជូនយោធិន និងគ្រួសារយោធិនរំសាយទៅកាន់មូលដ្ឋានដែលគេត្រូវទៅរស់នៅ ។
- បូកសរុបលទ្ធផលការងាររំសាយទ័ពជាក់ស្តែង ដើម្បីរាយការណ៍ជាប្រចាំជូនអគ្គលេខាធិការដ្ឋាន អំពីការវិវត្តន៍ដែលទាក់ទិនទៅនឹងការរស់នៅតាមមូលដ្ឋានរបស់យោធិនរំសាយ ។

**គ-ការងារក្រោយពេលរំសាយ**

**ការងារសមាហរណកម្ម**

- សហការជាមួយអគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សារំសាយកងកំលាំងប្រដាប់អាវុធ ដើម្បីអនុវត្តកម្មវិធីជំនួយឧបត្ថម្ភផ្តល់យោធិនរំសាយ ។
- សហការជាមួយអគ្គលេខាធិការដ្ឋាន ចុះសិក្សាស្រាវជ្រាវ វាយតំលៃអំពីស្ថានការណ៍រស់នៅរបស់យោធិន រំសាយនៅតាមមូលដ្ឋាន ។
- សហការជាមួយអគ្គលេខាធិការដ្ឋាន អង្គការអន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាលចុះពិនិត្យឧបត្ថម្ភ របស់កម្មវិធីរំសាយទ័ព តាមផែនការដែលបានគ្រោងទុក ។
- សហការជាមួយអគ្គលេខាធិការដ្ឋាន អង្គការក្រៅរដ្ឋាភិបាល និងស្ថាប័នដែលមានការពាក់ព័ន្ធ ដើម្បីចុះពិនិត្យមើលលើការងារព្យាបាលជំងឺ និងការបំពាក់អវយវៈសិប្បនិម្មិតជូនយោធិនរំសាយមុខសញ្ញាពិការ ។
- សហការជាមួយអគ្គលេខាធិការដ្ឋាន អង្គការអន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាលធ្វើផែនការបណ្តុះបណ្តាលវិជ្ជាជីវៈដែលសមស្របទៅតាមទីផ្សារការងារ និងមុខរបរនៅតាមមូលដ្ឋាន ដែលយោធិនកំពុងរស់នៅតាមលទ្ធភាព សមត្ថភាពរបស់យោធិនរំសាយម្នាក់ៗ ។
- សហការជាមួយអគ្គលេខាធិការដ្ឋាន អង្គការអន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាលដើម្បីរៀបចំផែនការ ការដោះស្រាយរកការងារអោយធ្វើដល់យោធិនរំសាយ តាមមុខជំនាញ ដែលបានបណ្តុះបណ្តាល ព្រមទាំងពិនិត្យនិងដោះស្រាយរាល់សំណូមពរចាំបាច់របស់យោធិនរំសាយក្នុងសហគមន៍តាមលទ្ធភាពជាក់ស្តែង ។

**ការងារអភិវឌ្ឍន៍សហគមន៍**

- សហការជាមួយអង្គការអន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាល ដើម្បីជួយឧបត្ថម្ភជីវភាពអតីតយុទ្ធជន និងគ្រួសាររបស់ពួកគេ តាមលទ្ធភាពជាក់ស្តែង ។
- សហការជាមួយអគ្គលេខាធិការដ្ឋាននិងស្ថាប័នរដ្ឋ ដើម្បីជួយសំរួលរាល់បញ្ហាដែលទាក់ទងនឹងយោធិនរំសាយ និងគ្រួសាររបស់ពួកគេនៅតាមមូលដ្ឋាន ជាពិសេសបង្កលក្ខណៈងាយស្រួលក្នុងការរកដីធ្លីជូនយោធិនរំសាយ ។

- តាមដាន និងត្រួតពិនិត្យលើការងារអភិវឌ្ឍន៍សហគមន៍ដែលយោធិនរំសាយកំពុងរស់នៅ និង អំពីផលប៉ះពាល់ផ្សេងៗ ដើម្បីប្រមូលសរុបលទ្ធផលការងារជាប្រចាំ រាយការណ៍ជូនអគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សារំសាយកងកំលាំងប្រដាប់អាវុធ ។

មាត្រា ៥ .- លេខាធិការរបស់គណៈកម្មការអតីតយុទ្ធជនខេត្ត ត្រូវចូលរួមប្រជុំពិភាក្សាការងារតាមការអញ្ជើញរបស់ប្រធានគណៈកម្មការ ។

មាត្រា ៦ .- អនុក្រឹត្យនេះ មានអានុភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

មាត្រា ៧ .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីនៃបណ្តាក្រសួង និង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ។

រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

## អនុក្រឹត្យ លេខ ១០៧ អនក្រ.តត

## ស្តីពី

## ការតែងតាំង តម្លើងឋានន្តរសក្តិ និងផ្លាស់ប្តូរ មុខងារនាយទាហាន នៃកងយោធពលខេមរភូមិន្ទ

***

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/៩៤/០២ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការពារជាតិ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០១៩៩/២១ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ ១៩៩៩ ស្តីពីការកែសម្រួលតួនាទីភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងអគ្គបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ

-បានឃើញអនុក្រឹត្យលេខ ៣៧ អនក្រ/បក ចុះថ្ងៃទី១៦ ខែ កុម្ភៈ ឆ្នាំ ១៩៩៩ ស្តីពីការកែសម្រួលរចនាសម្ព័ន្ធចាត់តាំង ក្រសួងការពារជាតិ

-យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

## សំរេច

មាត្រា ១ .- ត្រូវបានតែងតាំង ផ្លាស់ប្តូរមុខងារនិងតម្លើងឋានន្តរសក្តិនាយទាហាន នៃកងយោធពលខេមរភូមិន្ទ ដែលមាននាមដូចខាងក្រោម ៖

ក-តែងតាំង និងផ្លាស់ប្តូរមុខងារ :

| | | | |
|---|---|---|---|
| ១-វរសេនីយ៍ឯក | មិន នឹម | អត្តលេខ ០០០៣៦០ | នាយសេនាធិការរង យោធភូមិភាគទី៣ បច្ចុប្បន្ន ជាមេបញ្ជាការតំបន់ប្រតិបត្តិការសឹករង កំពង់ស្ពឺ |
| ២-វរសេនីយ៍ឯក | ឡឹក ម៉ុនឡី | អត្តលេខ ០០០២៣១ | នាយករង នាយកដ្ឋាន អធិការកិច្ច ក្រសួងការពារជាតិ បច្ចុប្បន្នជា យោធាចារ្យ សាលាលោកព្រឹត សាលាយោធា |
| ៣-វរសេនីយ៍ឯក | គឹម សុគ័ណ្ណ | អត្តលេខ ០០០៥៦៩ | មេបញ្ជាការកងរេហ៍ បញ្ជាការដ្ឋាន កងទ័ពអាកាស បច្ចុប្បន្នជាយោធាចារ្យ សាលាកនាយទាហានចំរុះ |
| ៤-វរសេនីយ៍ឯក | សួន សុពល | អត្តលេខ ០០០៥១៩ | មេបញ្ជាការរង កងពលធំលេខ៨ បច្ចុប្បន្នជា នាយករង នាយកដ្ឋានពលសេនា |
| ៥-វរសេនីយ៍ឯក | ផាន់ សាមន្តា | អត្តលេខ០០១១៨៨ | នាយករងទីចាត់ការកលល្បិច អគ្គបញ្ជាការដ្ឋាន បច្ចុប្បន្នជា នាយករង នាយកដ្ឋាន សោធននិវត្តន៍ |
| ៦-វរសេនីយ៍ឯក | មាស សក្តិ | អត្តលេខ ០០៧៥៧ | នាយសេនាធិការរង កងអន្តរាគមន៍ អគ្គសេនាធិការ បច្ចុប្បន្នជា នាយករងអធិការកិច្ច អគ្គបញ្ជាការដ្ឋាន |

| | | | |
|---|---|---|---|
| ៧-វរសេនីយ៍ឯក | ឆេង សុផា | អត្តលេខ ០០០៣២០ | នាយទាហានរង់ចាំបញ្ជាការដ្ឋានកាំភ្លើងធំ បច្ចុប្បន្នជានាយករងសាលានាយទាហានចំរុះ |
| ៨-វរសេនីយ៍ឯក | រស់ សុត | អត្តលេខ ០០០៣៧៨ | មេបញ្ជាការរង កងពលធំលេខ ៣ បច្ចុប្បន្នជានាយករង ទីចាត់ការគីមីសាស្ត្រ អគ្គបញ្ជាការដ្ឋាន |
| ៩-វរសេនីយ៍ឯក | អ៊ុត សាខន | អត្តលេខ ០០០៣៧៥ | មេបញ្ជាការតំបន់ប្រតិបត្តិការសឹករង ឧត្តរមានជ័យ បច្ចុប្បន្នជានាយករងទីចាត់ការគីមីសាស្ត្រ អគ្គបញ្ជាការដ្ឋាន |
| ១០-វរសេនីយ៍ឯក | ពុទ្ធ សារ៉ាន់ | អត្តលេខ ០០០៤៩០ | នាយករង ទីចាត់ការ ចលនូបត្ថម្ភ អគ្គបញ្ជាការដ្ឋានបច្ចុប្បន្នជានាយសេនាធិការរង បញ្ជាការដ្ឋានកងរាជអាវុធហត្ថ លើផ្ទៃប្រទេស |
| ១១-វរសេនីយ៍ឯក | ឡេង សារិន | អត្តលេខ ០០០៣៧៦ | មេបញ្ជាការកងពលធំលេខ៣ បច្ចុប្បន្នជានាយករងទីចាត់ការបច្ចេកទេស អគ្គបញ្ជាការដ្ឋាន |
| ១២-វរសេនីយ៍ឯក | ឡេង ឃីលី | អត្តលេខ ០០០៤៧៩ | នាយករងទីចាត់ការបុគ្គលិក អគ្គបញ្ជាការដ្ឋាន បច្ចុប្បន្នជាមេបញ្ជាការរងបញ្ជាការដ្ឋានបញ្ជូនសារ អគ្គបញ្ជាការដ្ឋាន |
| ១៣-វរសេនីយ៍ឯក | ឡឹង ជឿម | អត្តលេខ ០០០៥៥១ | នាយករង ទីចាត់ការកិច្ចការទូទៅ អគ្គបញ្ជាការដ្ឋាន បច្ចុប្បន្នជាមេបញ្ជាការរងបញ្ជាការដ្ឋានបញ្ជូនសារ អគ្គបញ្ជាការដ្ឋាន |
| ១៤-វរសេនីយ៍ឯក | ខៀវ សត្យា | អត្តលេខ ០០១២៤៣ | នាយករងទីចាត់ការចលនូបត្ថម្ភ អគ្គបញ្ជាការដ្ឋាន បច្ចុប្បន្នជានាយករងទីចាត់ការ ហិរញ្ញវត្ថុ អគ្គបញ្ជាការដ្ឋាន |
| ១៥-វរសេនីយ៍ឯក | អ៊ុក ជាវីត | អត្តលេខ ០០០៥០៣ | នាយករងទីចាត់ការបុគ្គលិក |

អគ្គបញ្ជាការដ្ឋាន បច្ចុប្បន្នជា
នាយករង ទីចាត់ការ អភិវឌ្ឍន៍
អគ្គបញ្ជាការដ្ឋាន

១៦-វរសេនីយ៍ឯក ឆាយ សុវណ្ណ អត្តលេខ ០០០៧៦៩ មេបញ្ជាការ កងពលតូចលេខ២
ម៉ាក់ព្រៃបច្ចុប្បន្នជានាយករងសាលា
នាយទាហានសកម្ម

១៧-វរសេនីយ៍ឯក នេត ណាត អត្តលេខ ០០០៤៩៨ នាយករងអធិការកិច្ច
អគ្គបញ្ជាការដ្ឋាន បច្ចុប្បន្នជា
នាយករងសាលានាយទាហាន
សកម្ម

១៨-វរសេនីយ៍ឯក ម៉ែន សារ៉ែន អត្តលេខ ០០០៨៣៦ មេបញ្ជាការរង កងពលធំលេខ៥
បច្ចុប្បន្នជា នាយករង សាលាជំនាញ
ឯកទេសចំរុះ

១៩-វរសេនីយ៍ឯក មុំ សាម៉ុន អត្តលេខ ០០០៣៩១ មេបញ្ជាការ រង កងពលធំលេខ៩
បច្ចុប្បន្នជា នាយករង សាលាជំនាញ
ឯកទេសចំរុះ

២០-វរសេនីយ៍ឯក សុខ ខេម អត្តលេខ ០០០៤៥៩ អនុបញ្ជាការរង មូលដ្ឋានពោធិចិន
តុង បញ្ជាការដ្ឋានកងទ័ពអាកាស បច្ចុប្បន្នជា ជំនួយការផ្ទាល់ ឧត្តមសេនីយ៍ឯក ជា សាន នាយរង
សេនាធិការចំរុះ នាយកទីចាត់ការកលយុទ្ធ អគ្គបញ្ជាការដ្ឋាន

២១-វរសេនីយ៍ឯក គឹម ម៉ុនណាត អត្តលេខ ០០០៣៦៩ នាយសេនាធិការរងយោធភូមិភាគ
ទី៤ បច្ចុប្បន្នជាជំនួយការផ្ទាល់ ឧត្តមសេនីយ៍ឯក ជា សាន នាយរងសេនាធិការចំរុះ នាយកទីចាត់ការ
កលយុទ្ធ អគ្គបញ្ជាការដ្ឋាន

២២-វរសេនីយ៍ឯក ឌិន ពិន អត្តលេខ ០០០៣៩៣ នាយសេនាធិការកងពលធំលេខ៩
បច្ចុប្បន្នជា យោធាចារ្យសាលា
បណ្តុះបណ្តាលយោធា

២៣-វរសេនីយ៍ឯក យ៉ាន សាវឌ្ឍ អត្តលេខ ០០០៥០៦ នាយករងទីចាត់ការកលយុទ្ធ
អគ្គបញ្ជាការដ្ឋាន បច្ចុប្បន្នជា
យោធាចារ្យសាលានាយទាហាន
ចំរុះ

២៤-វរសេនីយ៍ឯក ម៉ឹក សាខន អត្តលេខ ០០១០៩៧ ការពារផ្ទាល់ កងពលតូចលេខ៧០

បច្ចុប្បន្នជា លេខាផ្ទាល់ ឧត្តមសេនីយ៍ឯកខាន់ សាវឿន អគ្គមេបញ្ជាការរង នៃកងយោធពលខេមរភូមិន្ទ

២៥-វរសេនីយ៍ឯក គង់ សាវឿន អត្តលេខ ១០០៨១៩ នាយសេនាធិការរងសេនាធិការដ្ឋានកងអន្តរាគមន៍ អគ្គបញ្ជាការដ្ឋាន បច្ចុប្បន្នជានាយរង ការិយាល័យទី២ កងទ័ពជើងគោក

២៦-វរសេនីយ៍ឯក ជ័យ សែន អត្តលេខ ០០០៥០៧ នាយករង ទីចាត់ការហ្វឹកហ្វឺន អគ្គបញ្ជាការដ្ឋានបច្ចុប្បន្នជា នាយរង ការិយាល័យហ្វឹកហ្វឺន កងទ័ពជើងគោក

២៧-វរសេនីយ៍ឯក សុខ សាវ៉ាត អត្តលេខ ០០០៨៧៧ នាយទាហានរង ចាំទីចាត់ការបុគ្គលិកអគ្គបញ្ជាការដ្ឋាន បច្ចុប្បន្នជា នាយរង ការិយាល័យហ្វឹកហ្វឺន កងទ័ពជើងគោក

២៨-វរសេនីយ៍ឯក ស្រី សុផល អត្តលេខ ០០១០៨៥ មេបញ្ជាការរង និង ជានាយសេនាធិការកងពលតូចលេខ៧០ បច្ចុប្បន្នជានាយសេនាធិការរងយោធភូមិភាគពិសេស

២៩-វរសេនីយ៍ឯក ចៅ ឧន អត្តលេខ ០០០៣៨០ មេបញ្ជាការរង កងពលធំលេខ៩ បច្ចុប្បន្នជា នាយសេនាធិការរងយោធភូមិភាគពិសេស

៣០-វរសេនីយ៍ទោ រស់ សាវណ្ណ អត្តលេខ ០០០៥៤៦ នាយលេខាធិការដ្ឋាន បច្ចុប្បន្នជានាយករងនាយកដ្ឋានកិច្ចការយោធាស៊ីវិល

៣១-វរសេនីយ៍ទោ សុខ វណ្ណារ៉ា អត្តលេខ ០០០៥៦៧ នាយករងនាយកដ្ឋាន ហិរញ្ញវត្ថុ និងជា នាយការិយាល័យ ផែនការ អគ្គនាយកដ្ឋានភស្តុភា-ហិរញ្ញវត្ថុ

៣២-វរសេនីយ៍ទោ ស៊ីង ខាំចាន់តារ៉ុង អត្តលេខ០០១១៦៦ នាយករង នាយកដ្ឋាន ឃោសនា និងជា នាយការិយាល័យ ផែនការ អគ្គនាយកដ្ឋានយោធសេវា

៣៣-វរសេនីយ៍ទោ អោម ទិចិត្រ អត្តលេខ ០០០៥៦៨ នាយករង នាយកដ្ឋានបច្ចេកទេស និងជានាយការិយាល័យ ផែនការ

អគ្គនាយកដ្ឋានសំភារៈបច្ចេកទេស

៣៤-វរសេនីយ៍ទោ ម៉ូ សុខគីម អត្តលេខ ០០០៩៣៣ មេបញ្ជាការរង តំបន់ប្រតិបត្តិការ សឹករង កំពង់ស្ពឺ បច្ចុប្បន្នជានាយសេនាធិការរង យោធភូមិភាគទី៣

៣៥-វរសេនីយ៍ទោ ម៉ូ ផាន់សារី អត្តលេខ ០០០៦១៣ នាយការិយាល័យបច្ចេកទេស បច្ចុប្បន្នជា នាយករង នាយកដ្ឋានវិស្វកម្ម

៣៦-វរសេនីយ៍ទោ ខឹម សុខ អត្តលេខ ០០០៦១១ នាយការិយាល័យ សំណង់អាគារ បច្ចុប្បន្នជា នាយករង នាយកដ្ឋានវិស្វកម្ម

៣៧-វរសេនីយ៍ទោ ឡោក ឆាយ អត្តលេខ ០០៣៦១២ ជំនួយការផ្ទាល់ សម្តេច ជា ស៊ីម ប្រធាន ព្រឹទ្ធសភា

៣៨-វរសេនីយ៍ទោ ស៊ឹម សុភាព អត្តលេខ ០០០៦០៥ នាយសេនាធិការដ្ឋាន អគ្គនាយកដ្ឋាន យោធសេវា បច្ចុប្បន្ន ជានាយករង នាយកដ្ឋានសោធននិវត្តន៍

៣៩-វរសេនីយ៍ទោ ម៉ឹម សំ អត្តលេខ ០០២៥១២ លេខាផ្ទាល់ ឧត្តមសេនីយ៍ឯក ម៉ុល សារឿន អគ្គមេបញ្ជាការរង និងជានាយសេនាធិការចំរុះ

៤០-វរសេនីយ៍ទោ ហេង ទុន្នី អត្តលេខ ០០១២១៣ នាយលេខាធិការដ្ឋានសាលាបណ្ឌិតសភាយោធា បច្ចុប្បន្នជា នាយករង ទីចាត់ការអភិវឌ្ឍន៍ អគ្គបញ្ជាការដ្ឋាន

៤១-វរសេនីយ៍ទោ អ៊ុក សំអាត អត្តលេខ ០០២១១៣ នាយការិយាល័យស្រាវជ្រាវភូមិសាស្ត្រ ទីចាត់ការ ការងារព្រំដែន អគ្គបញ្ជាការដ្ឋាន បច្ចុប្បន្នជា នាយការិយាល័យបំរ៉ែនអគ្គិរៈ កងទ័ពជើងគោក

៤២-វរសេនីយ៍ទោ ឡេង លីម អត្តលេខ ០០១៩៤០ នាយផ្នែកបូកសរុប ឧទ្ទកាល័យ អគ្គសេនាធិការ បច្ចុប្បន្នជា នាយរងឧទ្ទកាល័យ កងទ័ពជើងគោក

៤៣-វរសេនីយ៍ទោ ធន់ តារាវណ្ណ អត្តលេខ ០០០៦៤២ នាយទាហានរងចាំ បញ្ជាការដ្ឋាន កងទ័ពជើងគោក

៤៤-វរសេនីយ៍ទោ ចាន់ វណ្ណា អត្តលេខ ០០២៣១៩ នាយសេនាធិការរង កងពលតូច

លេខ៧០ បច្ចុប្បន្នជា មេបញ្ជាការរង និងជានាយសេនាធិការ កងពលតូចលេខ៧០

៩៥-វរសេនីយ៍ទោ ឆេត ឆម អត្តលេខ ០០០៦៨៩ នាយទាហានទីចាត់ការឃោសនា ពត៌មាន អគ្គបញ្ជាការដ្ឋាន បច្ចុប្បន្នជា នាយសេនាធិការរង យោធភូមិភាគទី៥

៩៦-វរសេនីយ៍ទោ ស៊ីន សារ៉េត អត្តលេខ ០០១០០៦ មេបញ្ជាការវរសេនាធំ លេខ៣៣ កងពលធំលេខ១១ យោធភូមិភាគទី៤ បច្ចុប្បន្នជា មេបញ្ជាការរង កងពលធំលេខ១១ យោធភូមិភាគទី៤

៩៧-វរសេនីយ៍ឯក ឯម សុគន្ធ អត្តលេខ ០០០៥១០ នាយករងទីចាត់ការកិច្ចការទូទៅ អគ្គមេបញ្ជាការដ្ឋាន បច្ចុប្បន្នជា នាយសេនាធិការរង យោធភូមិភាគទី២

៩៨-វរសេនីយ៍ឯក ញ៉ៀម សុខេខ អត្តលេខ ០០០៣២៣ មេបញ្ជាការរងបញ្ជាការដ្ឋានកាំភ្លើងធំ អគ្គបញ្ជាការដ្ឋាន បច្ចុប្បន្នជា នាយសេនាធិការរង យោធភូមិភាគទី៥

៩៩-វរសេនីយ៍ឯក ឈាន ឆន អត្តលេខ ០០១០០៤ នាយរង ការិយាល័យទី៣ កងទ័ពជើងគោក បច្ចុប្បន្នជា នាយរង ការិយាល័យការពារព្រំដែន កងទ័ពជើងគោក

៥០-វរសេនីយ៍ឯក អ៊ិន ទិត្យមិត្ត អត្តលេខ ០០០៨៨២ នាយសេនាធិការរង យោធភូមិភាគទី១ បច្ចុប្បន្នជា នាយរង ការិយាល័យការពារព្រំដែន កងទ័ពជើងគោក

៥១-វរសេនីយ៍ឯក សេ ទាសនា អត្តលេខ ០០១៨៩៧ នាយរងខុទ្ទកាល័យ កងទ័ពជើងគោក បច្ចុប្បន្នជា នាយរង ការិយាល័យការពារព្រំដែន កងទ័ពជើងគោក

៥២-វរសេនីយ៍ឯក មិត្ត ម៉ុនតេ្ថ អត្តលេខ ០០០៣៦២ នាយសេនាធិការរង យោធភូមិភាគទី៣ បច្ចុប្បន្នជា នាយរង ការិយាល័យការពារព្រំដែន កងទ័ពជើងគោក

៥៣-វរសេនីយ៍ឯក នាក់ ស៊ីថាន់ អត្តលេខ ០០១២២៥ មេបញ្ជាការរង កងពលតូចទ័ពពិសេស ឆ័ត្រយោង ៩១១ បច្ចុប្បន្នជា នាយការិយាល័យស្រាវជ្រាវ ភូមិសាស្ត្រ ទីចាត់ការការងារព្រំដែន អគ្គបញ្ជាការដ្ឋាន

៥៤-វរសេនីយ៍ឯក អ៊ុច សំណាង អត្តលេខ ០០០៦៥៣ នាយករង ទីចាត់ការផែនការ អគ្គបញ្ជាការដ្ឋាន បច្ចុប្បន្នជា នាយការិយាល័យបុគ្គលិក ខុទ្ទកាល័យ អគ្គបញ្ជាការដ្ឋាន

៥៥-វរនារីឯក ម៉ាន់ ស៊ីវណ្ណា អត្តលេខ ០០១១១៨ មេបញ្ជាការមូលដ្ឋានទន្លេបញ្ជាការដ្ឋានកងទ័ពជើងទឹក បច្ចុប្បន្នជា នាយសេនាធិការរង បញ្ជាការដ្ឋានកងទ័ពជើងទឹក

៥៦-វរសេនីយ៍ឯក ស៊ុន សុផល អត្តលេខ ០០១០១៩ មេបញ្ជាការតំបន់អភិវឌ្ឍន៍យោធភូមិភាគទី៥ បច្ចុប្បន្នជា នាយសេនាធិការរង យោធភូមិភាគទី៥

៥៧-វរសេនីយ៍ឯក ចិក ខឹម អត្តលេខ ០០៣៩១៤ មេបញ្ជាការរង កងពលធំលេខ ១៨ បច្ចុប្បន្នជា មេបញ្ជាការតំបន់អភិវឌ្ឍន៍ យោធភូមិភាគទី៥

ខ-តែងតាំង និងតម្លើងឋានន្តរសក្តិថ្នាក់វរសេនីយ៍ឯក និងថ្នាក់វរនាវីឯក

១-វរសេនីយ៍ទោ កែវ ច័ន្ទតារា អត្តលេខ ០០០៦២៧ នាយករងសាលាមធ្យមសិក្សាពេទ្យខេមរភូមិន្ទ

២-វរសេនីយ៍ទោ សែម សុខុន អត្តលេខ ០០០៦២៨ នាយករងសាលាមធ្យមសិក្សាពេទ្យខេមរភូមិន្ទ

៣-វរសេនីយ៍ទោ គួក់ លន់ អត្តលេខ ០០០៦២៩ នាយករងសាលាមធ្យមសិក្សាពេទ្យខេមរភូមិន្ទ

៤-វរសេនីយ៍ទោ ឡៅម ថៃវ៉ាន់ អត្តលេខ ០០០៦២០ នាយករង មន្ទីរពេទ្យព្រះកេតុមាលា

៥-វរសេនីយ៍ទោ គុម សារ៉ន អត្តលេខ ០០០៦២១ នាយករង មន្ទីរពេទ្យព្រះកេតុមាលា

៦-វរសេនីយ៍ទោ អៀង អឿន អត្តលេខ ០០០៦២២ នាយករង មន្ទីរពេទ្យព្រះកេតុមាលា

៧-វរសេនីយ៍ទោ ព្រហ្ម ឌីក អត្តលេខ ០០១៦៥១ នាយការិយាល័យសហប្រតិបត្តិការ បច្ចុប្បន្នជា នាយករង នាយកដ្ឋាន ទាក់ទងអន្តរជាតិ

៨-វរសេនីយ៍ទោ នួន សំបូរ អត្តលេខ ០០០៥៥៦ នាយការិយាល័យផលិត បច្ចុប្បន្នជា នាយករង នាយកដ្ឋាន ភូមិសាស្ត្រ

៩-វរនាវីទោ នេត ស៊ីម្រួ អត្តលេខ ០០១១១០ នាយផ្នែកបច្ចេកទេសបញ្ជាការដ្ឋានកងទ័ពជើងទឹក បច្ចុប្បនជា នាយសេនាធិការរង បញ្ជាការដ្ឋានកងទ័ពជើងទឹក

១០-វរនាវីទោ ហ៊ីង ពុធតារា អត្តលេខ ០០១១១៣ មេបញ្ជាការរងមូលដ្ឋាន សមុទ្របញ្ជាការដ្ឋាន កងទ័ពជើងទឹក

១១-វរនាវីទោ ចាន់ សុផល អត្តលេខ ០០១១១៤ មេបញ្ជាការរង មូលដ្ឋានសមុទ្របញ្ជាការដ្ឋានកងទ័ពជើងទឹក

១២-វរនាវីទោ ហង្ស មន អត្តលេខ ០០២៥៣៣ មេបញ្ជាការរង មូលដ្ឋានសមុទ្របញ្ជាការដ្ឋានកងទ័ពជើងទឹក

១៣-វរសេនីយ៍ទោ អ៊ុំ ម៉ាំង អត្តលេខ ០០១១២៨ ជំនួយការ ឧត្តមសេនីយ៍ឯក គៀង សាវុធ ទីប្រឹក្សា សម្តេចនាយករដ្ឋមន្ត្រី

១៤-វរសេនីយ៍ទោ ជេត សាម៉េត អត្តលេខ ០០២៥៦៧ ជំនួយការ ឧត្តមសេនីយ៍ឯក គៀង សាវុធ ទីប្រឹក្សា សម្តេចនាយករដ្ឋមន្ត្រី

១៥-វរសេនីយ៍ទោ គុម សារុំ អត្តលេខ ០០០៩១៣ មេបញ្ជាការរង តំបន់ប្រតិបត្តិការសឹករង កំពង់ចាម

១៦-វរសេនីយ៍ទោ តាន់ ថាណា អត្តលេខ ០០១៩៥១ នាយអង្គភាព ផលិតស្បៀងក្រៀមនាយកដ្ឋានផ្គត់ផ្គង់ បច្ចុប្បន្នជា នាយករង នាយកដ្ឋានផ្គត់ផ្គង់

មាត្រា ២ .- បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣ .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃ ចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

***

# អនុក្រឹត្យ លេខ ១០៨ អនក្រ.តត

## ស្តីពី

## ការតែងតាំង មន្ត្រីរាជការ

***

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/៩៤/០២ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី

-បានឃើញអនុក្រឹត្យលេខ ៧៦/អនក្រ/បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ១៩៩៨ ស្តីពីការបង្កើតខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

-យោងតាមសំណូមពរការងារចាំបាច់របស់រាជរដ្ឋាភិបាលកម្ពុជា

## សំរេច

មាត្រា ១ .- ត្រូវបានតែងតាំងលោក ហ៊ីង ប៊ុនហៀង ជានាយករង ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា បន្ថែមលើមុខងារបច្ចុប្បន្ន ។

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃ ចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

★★★

## អនុក្រឹត្យ លេខ ១០៩ អនក្រ.តត

## ស្តីពី

## ការតែងតាំង មន្ត្រីរាជការ

***

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/៩៤/០២ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី

-បានឃើញអនុក្រឹត្យលេខ ៧៦/អនក្រ/បក ចុះថ្ងៃទី០១ ខែ ធ្នូ ឆ្នាំ ១៩៩៨ ស្តីពីការបង្កើតខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

-យោងតាមសំណូមពរការងារចាំបាច់របស់រាជរដ្ឋាភិបាលកម្ពុជា

## សំរេច

**មាត្រា ១ .-** ត្រូវបានតែងតាំងលោក **ហ៊ុយ ពិសិដ្ឋ** ជានាយករងខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា បន្ថែមលើមុខងារបច្ចុប្បន្ន ។

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃ ចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

# អនុក្រឹត្យ លេខ ១១០ អនក្រ.តត

## ស្ដីពី

## ការជូនមេដាយសហមេត្រី

***

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/រកម/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្ដីពីការប្រកាសឲ្យប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

## សំរេច

**មាត្រា ១ .-** ត្រូវបានប្រគល់ មេដាយសហមេត្រី តាមលំដាប់ថ្នាក់ជូនជំនាញការ អ្នកបកទេសជនជាតិជប៉ុន ឥណ្ឌូណេស៊ី ម៉ាឡេស៊ី ហ្វីលីពីន និងថៃឡង់ដ៍ ចំនួន ១៨រូប ដែលបានខិតខំបំពេញការងារ សំរេចបានស្នាដៃល្អប្រសើរ ក្នុងបេសកកម្មជាដៃគូ ក្នុងគំរោងអភិវឌ្ឍន៍ជនបទ សំដៅកាត់បន្ថយនូវភាពក្រីក្រនៅតាមជនបទនៃខេត្តកំពង់ស្ពឺ និងខេត្តតាកែវ ដូចមានរាយនាមខាងក្រោម នេះ ÷

ក-មេដាយសេនាសហមេត្រី :

| | | |
|---|---|---|
| ១-លោក | Fujita Takao | ជំនាញការ JICA និងជាប្រធានគំរោង |
| ២-លោក | Alrisman Agoes | ប្រធានក្រុមអ្នកឯកទេសឥណ្ឌូណេស៊ី |
| ៣-អ្នកស្រី | Rebecca T.Lacson | ប្រធានក្រុមអ្នកឯកទេសហ្វីលីពីន |

ខ-មេដាយអស្សឫទ្ធិសហមេត្រី :

| | | |
|---|---|---|
| ១-លោក | Iwayan Marthayasa | អ្នកឯកទេសឥណ្ឌូណេស៊ី |
| ២-លោក | Domingo P.Nilo | អ្នកឯកទេសផ្នែកដំណាំរួមផ្សំ |
| ៣-លោក | Leonardo C. DeGuzman | អ្នកឯកទេសផ្នែកបង្កាត់ផ្សាំដើមឈើ |
| ៤-លោក | A.S. Syamasudin | អ្នកឯកទេសឥណ្ឌូណេស៊ី |
| ៥-លោក | Nicolaus Rinda | អ្នកឯកទេសឥណ្ឌូណេស៊ី |
| ៦-លោក | Bambang Wiji Santoso | អ្នកឯកទេសឥណ្ឌូណេស៊ី |
| ៧-លោក | Mohamad ZUKI BIN ABU BAKAR | ប្រធានក្រុមអ្នកឯកទេសម៉ាឡេស៊ី |

៨-លោក Roben B. Miranda អ្នកឯកទេសហ្វីលីពីន
៩-អ្នកស្រី Ma Helen Rantugan អ្នកឯកទេសហ្វីលីពីន
១០-អ្នកស្រី Lina C.Lapitan អ្នកឯកទេសហ្វីលីពីន
១១-លោក Boonrawd . Thongdonphum ប្រធានក្រុមអ្នកឯកទេសថៃ
១២-លោក Panupan Vannasurachat អ្នកឯកទេសថៃ
១៣-លោក Sanit Manu Ekkul អ្នកឯកទេសថៃ
១៤-លោក Sawaeng Gaewprasang អ្នកឯកទេសថៃ
១៥-អ្នកស្រី Kanan Onanong អ្នកឯកទេសថៃ

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផល ។

រាជធានីភ្នំពេញ,ថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០០០
នាយករដ្ឋមន្ត្រី
ហត្ថលេខា និងត្រា
ហ៊ុន សែន

***

## អនុក្រឹត្យ លេខ ១១១ អនក្រ.តត
## ស្តីពី
## ការ តែងតាំងមន្ត្រីរាជការ

***

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៧២ ចុះថ្ងៃទី១៩ ខែ មីនា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ

-បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ/បក ចុះថ្ងៃទី១២ ខែ ឧសភា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតក្រុមប្រឹក្សារំសាយកងកំលាំងប្រដាប់អាវុធ

-បានឃើញអនុក្រឹត្យលេខ ៩២ អនក្រ/បក ចុះថ្ងៃទី១២ ខែ ធ្នូ ឆ្នាំ ១៩៩៩ ស្ដីពីការបង្កើតអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សារំសាយកងកំលាំងប្រដាប់អាវុធ

-យោងសេចក្ដីជូនដំណឹងលេខ ២០៩ សជណសរ ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ ២០០០ ស្ដីពីលទ្ធផល នៃសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នាថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ២០០០

-តាមសំណើរបស់ប្រធានក្រុមប្រឹក្សារំសាយកងកំលាំងប្រដាប់អាវុធ

## សំរេច

**មាត្រា ១ .-** ត្រូវបានតែងតាំងអស់លោក ដែលមានរាយនាមដូចខាងក្រោម :

១-លោក អ៊ុក រិន ជាប្រធាននាយកដ្ឋានរដ្ឋបាល និង បុគ្គលិក នៃក្រុមប្រឹក្សារំសាយកងកំលាំងប្រដាប់អាវុធ

២-លោក ម៉ក់ សារិន ជាប្រធាននាយកដ្ឋានប្រតិបត្តិការ និងភស្ដុភារ នៃក្រុមប្រឹក្សារំសាយកងកំលាំងប្រដាប់អាវុធ

៣-លោក ថោង សុជាតិ ជាប្រធាននាយកដ្ឋានហិរញ្ញវត្ថុ នៃក្រុមប្រឹក្សារំសាយកងកំលាំងប្រដាប់អាវុធ

៤-លោក ហេង សុខឃាង ជាប្រធាននាយកដ្ឋានសមាហរណកម្ម នៃក្រុមប្រឹក្សារំសាយកងកំលាំងប្រដាប់អាវុធ

៥-លោក សុខ្ន ធី ជាប្រធានមជ្ឈមណ្ឌលកុំព្យូទ័រ នៃក្រុមប្រឹក្សារំសាយកងកំលាំងប្រដាប់អាវុធ មានឋានៈស្មើប្រធាននាយកដ្ឋាន

**មាត្រា ២ .-** បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រីគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្ត អនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

# អនុក្រឹត្យ លេខ ១១២ អនក្រ.តត

## ស្តីពី

## ការ តែងតាំងមន្ត្រីរាជការ

***

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ/បក ចុះថ្ងៃទី២២ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសុខាភិបាល

-យោងតាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងសុខាភិបាល

## សំរេច

**មាត្រា ១ .-** តែងតាំងលោក វេជ្ជបណ្ឌិត សយ តិរម្យ ជាអគ្គាធិការរង នៃអគ្គាធិការដ្ឋាន ក្រសួងសុខាភិបាល ។

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ តាំងពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

***

# អនុក្រឹត្យ លេខ ១១៣ អនក្រ.តត

## ស្តីពី

## ការជូនមេដាយស្ថាបនាជាតិ

***

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកអភិបាលរាជធានីភ្នំពេញ

### សំរេច

មាត្រា ១ .- ត្រូវបានប្រគល់ មេដាយមាសស្ថាបនាជាតិ ជូនសមាគម OITA MINAMI LIONS CLUB ប្រទេសជប៉ុន ដែលបានផ្តល់ការកសាងអាគារសិក្សាមួយខ្នង នៅសាលាបឋមសិក្សាឫស្សីកែវ ចំណាយអស់ទឹកប្រាក់ចំនួន ២៧.៥០០ ដុល្លារអាមេរិក ។

មាត្រា ២ .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុក អភិបាលរាជធានីភ្នំពេញ ត្រូវអនុវត្តអនុក្រឹត្យនេះ ដោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

## អនុក្រឹត្យ លេខ ១១៤ អនក្រ.តត

## ស្តីពី

## ការជូនមេដាយស្ថាបនាជាតិ

***

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់អភិបាលខេត្តកំពត

**សំរេច**

មាត្រា ១ .- ត្រូវបានប្រគល់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជនជប៉ុន ដែលបានជួយកសាងអាគារសិក្សា មួយខ្នង នៅសាលាបឋមសិក្សាអង្គចោពញា ឃុំសត្វពង ស្រុកឈូក ខេត្តកំពត ដោយអស់ទឹកប្រាក់ចំនួន ៣៥.០០០ ដុល្លារអាមេរិក ដូចមានរាយនាមខាងក្រោម :

១-ក្រុមហ៊ុន **តាកេ្ធ ជូតូ ជប៉ុន**

២-លោកស្រី **ម៉ារីកូ អូកាម៉ូតូ** ប្រធានអង្គការ ASAC

មាត្រា ២ .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងអភិបាលខេត្តកំពត ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ។

រាជធានីភ្នំពេញ,ថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០០០

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**ហ៊ុន សែន**

★★★

**អនុក្រឹត្យ លេខ ១១៥ អនក្រ.តត**

**ស្តីពី**

**ការជូនមេដាយស្ថាបនាជាតិ**

***

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកអភិបាលរាជធានីភ្នំពេញ

**សំរេច**

មាត្រា ១ .- ត្រូវបានប្រគល់ **មេដាយមាសស្ថាបនាជាតិ** ជូនឯកឧត្តម **យិន ចិនអោយ** ឯកអគ្គរដ្ឋទូត នៃសាធារណរដ្ឋប្រជាមានិតចិន ប្រចាំព្រះរាជាណាចក្រកម្ពុជា ដែលបានជួយកសាងអាគារសិក្សាមួយខ្នង នៅសាលាបឋម

សិក្សាមិត្តភាព កម្ពុជា-ចិន ឃ្មួញ ក្នុងខ័ណ្ឌឫស្សីកែវ ចំណាយអស់ទឹកប្រាក់សរុបចំនួន ៣៥,១០០ ដុល្លារអាមេរិក ។

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកអភិបាលរាជធានីភ្នំពេញ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ,ថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

★★★

## អនុក្រឹត្យ លេខ ១១៦ អនក្រ.តត

## ស្តីពី

## ការជូនមេដាយស្ថាបនាជាតិ

***

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់អភិបាលខេត្តព្រៃវែង

## សំរេច

**មាត្រា ១ .-**ត្រូវបានប្រគល់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ប្រគេន និងជូនសប្បុរសជន ដែលបានជួយកសាងសាលាពុទ្ធិកវិទ្យាល័យព្រៃវែង រួមទាំងសំភារៈបរិក្ខារសិក្សាផ្សេងៗ ដូចមានរាយព្រះនាម និង នាមខាងក្រោមនេះ ៖

**ក-មេដាយមាសស្ថាបនាជាតិ :**

១-លោកប្រធានអង្គការសន្តិស៊ុគ្រចិត្ត (SVA) ឧបត្ថម្ភថវិកា ចំនួន ១០.២០០ US$

២-លោកប្រធានសមាគម សូតូស៊ូ ទីក្រុងមីយ៉ាហ្គី ប្រទេសជប៉ុន ឧបត្ថម្ភថវិកា ចំនួន ១០.២០០ US$

ខ-មេដាយប្រាក់ស្ថាបនាជាតិ :

-ព្រះតេជគុណ គឹម សាន់ ចៅអធិការវត្តសុវណ្ណរង្សី និងជានាយក ពុទ្ធិកវិទ្យាល័យ ព្រៃវែង ឧបត្ថម្ភថវិកា ចំនួន ៥.២០០ ដុល្លារអាមេរិក

គ-មេដាយសំរឹទ្ធស្ថាបនាជាតិ :

១-លោក យី ធន់ អតីតទីប្រឹក្សាអមក្រសួងធម្មការ និងសាសនា ឧបត្ថម្ភថវិកា ចំនួន ១.៦០០ US$

២-លោក ស សែត ប្រធានមន្ទីរធម្មការ និងសាសនា ខេត្តព្រៃវែង ឧបត្ថម្ភថវិកា ចំនួន ១.១៥០ US$

៣-លោក ចិន តាក់ អតីតប្រធានមន្ទីរធម្មការ និងសាសនា ខេត្តព្រៃវែង ឧបត្ថម្ភថវិកាចំនួន ១.១០០ US$

មាត្រា ២ .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងអភិបាលខេត្តព្រៃវែង ត្រូវអនុវត្តអនុក្រឹត្យនេះអោយ មានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

បណ្ឌិត សម្តេច

ហ៊ុន សែន

★★★

## អនុក្រឹត្យ លេខ ១១៧ អនក្រ.តត

## ស្តីពី

## ការជូនមេដាយស្ថាបនាជាតិ

***

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយ ប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការ ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

## សំរេច

មាត្រា ១ .- ត្រូវបានប្រគល់ មេដាយសេនាសហមេត្រី ជូនលោក Harald A.Wie តំណាងអចិន្ត្រៃយ៍ អង្គការជំនួយ របស់ប្រជាជន ន័រវេស្ស៍ (NPA) ដែលបានសហការយ៉ាងសកម្ម ជាមួយក្រសួងអភិវឌ្ឍន៍ជនបទ លើ

គំរោងអភិវឌ្ឍន៍សហគមន៍ និងតាំងទីលំនៅថ្មី នៅស្រុកថ្មពួក ស្រុកអូរជ្រៅ និងស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ។

មាត្រា ២ .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងអភិវឌ្ឍន៍ជនបទ ត្រូវអនុវត្ត អនុក្រឹត្យនេះអោយមានប្រសិទ្ធភាពលទ្ធផលល្អ ។

រាជធានីភ្នំពេញ,ថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

រាជធានីភ្នំពេញ,ថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០០០

## ២-សារាចរណែនាំ

### សារាចរណែនាំលេខ ០៣ សរណន

### ស្តីពី

### ការរៀបចំពិធីទិវាវប្បធម៌ជាតិ ៣ មេសា លើកទី២ នៃព្រះរាជាណាចក្រកម្ពុជា

***

អនុវត្តតាមស្មារតីអនុក្រឹត្យលេខ ២៤ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ១៩៩៩ រាជរដ្ឋាភិបាលបាន កំណត់យកថ្ងៃ ០៣ មេសា រៀងរាល់ឆ្នាំ ចាប់ពីឆ្នាំ ១៩៩៩ តទៅ ធ្វើជា ទិវាវប្បធម៌ជាតិ នៃព្រះរាជាណាចក្រកម្ពុជា ។

ឆ្នាំ ២០០០ បានក្លាយទៅជារបត់យ៉ាងសំខាន់ និងចាំបាច់មួយ សំរាប់មនុស្សជាតិ ព្រោះថា ឆ្នាំ២០០០ មិន ត្រឹមតែនាំមុខសតវត្សរ៍ថ្មីប៉ុណ្ណោះទេ ថែមទាំងនាំមុខសហស្សវត្សរ៍ថ្មីទៀតផង ។ ដោយហេតុស្ថានភាពវប្បធម៌ជាតិ យើង ដែលបាននិងកំពុងរងនូវការបំផ្លិចបំផ្លាញគ្រប់បែបយ៉ាងនោះ យើងត្រូវតែឆក់យកឱកាសដ៏វិសេសវិសាលនេះ ដើម្បីប្រារព្ធពិធី ទិវាវប្បធម៌ជាតិ ០៣មេសាលើកទី២ ដោយចាត់ទុកថា នេះជាឆ្នាំទី១ នៃការអនុវត្តនយោបាយ វប្បធម៌ សន្តិភាពនៅកម្ពុជានិងជាផ្នែកមួយរបស់ឆ្នាំអន្តរជាតិ នៃវប្បធម៌សន្តិភាពពិភពលោក ដោយយកប្រធានបទ " ការថែរក្សាការពារបេតិកភ័ណ្ឌជាតិ " ។

ការប្រារព្ធទិវាវប្បធម៌ជាតិ នាឆ្នាំនេះ ធ្វើឡើងក្នុងគោលបំណងដាស់ព្រលឹងខ្មែរគ្រប់រូប អោយក្រោកឡើង ព្រមៗគ្នា បញ្ចេញសកម្មភាពរួមគ្នាជាឯកច្ឆន្ទ និងជាបន្ទាន់ ក្នុងការលើកកំពស់ និងថែរក្សាវប្បធម៌ជាតិអោយបាន គង់វង្ស រួមចំណែកក្នុងការអភិវឌ្ឍន៍ប្រទេសជាតិ ប្រកបដោយលក្ខណៈចរិតជាតិ និងចំរើនជឿនលឿន និងជំរុញសន្តិ ភាព និងភាពអហិង្សានេះ អោយទៅជាផ្នត់គំនិតមួយ នៃជីវភាពរស់នៅប្រចាំថ្ងៃរបស់ខ្មែរអោយផុតថ្កើង និងថ្លៃថ្នូរ ដើម្បី បញ្ចៀសមនុស្សជំនាន់ក្រោយអោយផុតពីមហន្តរាយនៃសង្គ្រាម ។

ដើម្បីអោយការរៀបចំពិធី ទិវាវប្បធម៌ជាតិ ០៣មេសានេះប្រព្រឹត្តទៅបានល្អប្រសើរ រាជរដ្ឋាភិបាល សូមធ្វើការណែនាំដូចតទៅ ៖

១-គ្រប់ក្រសួង ស្ថាប័ន អាជ្ញាធរខេត្ត-ក្រុង គ្រប់វត្តអារាម គ្រឹះស្ថានសាធារណៈ ប្រព័ន្ធឃោសនា ក្រុមហ៊ុនឯកជន សមាគមនានា ត្រូវចូលរួមអបអរសាទរ ទិវាវប្បធម៌ជាតិ ព្រមទាំងបំផុស និងធ្វើការផ្សព្វផ្សាយអោយបានទូលំទូលាយ អំពីនយោបាយ វប្បធម៌ជាតិ អត្តសញ្ញាណជាតិ ស្មារតីការពារ ថែរក្សាវប្បធម៌ជាតិ សិល្បៈ បេតិកភ័ណ្ឌវប្បធម៌ជាតិ ទំនៀមទំលាប់ប្រពៃណីដ៏ល្អប្រពៃរបស់ជាតិយើង ។ បំផុសមន្ត្រីរាជការ បុគ្គលិក និយោជិត នគរបាល កងទ័ព សិស្សនិស្សិត ព្រះសង្ឃ និងប្រជាពលរដ្ឋគ្រប់ស្រទាប់ អោយលើកទង់ជាតិ បដានិងពាក្យស្លោក ។ ពេលយប់នៅរាជធានីភ្នំពេញ គ្រប់ខេត្ត-ក្រុង ខ័ណ្ឌ-ស្រុក ទីប្រជុំជនវត្តអារាម គប្បីតុបតែងលំអដោយភ្លើងអគ្គិសនីអោយបានភ្លឺព្រោងព្រាត ។

២-ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ត្រូវ ៖

-រៀបចំអត្ថបទ ដើម្បីធ្វើការផ្សព្វផ្សាយជាសាធារណៈ អំពីនយោបាយវប្បធម៌ជាតិ ស្មារតីការពារវប្បធម៌ សិល្បៈ បេតិកភណ្ឌវប្បធម៌ជាតិ ទំនៀមទំលាប់ប្រពៃណីដ៏ល្អប្រពៃរបស់ជាតិ និង ស្មារតីគោរពច្បាប់ និង បទប្បញ្ញត្តិនានា ស្តីពីការគ្រប់គ្រង និងការការពារវប្បធម៌ជាតិ និង បរិស្ថានជាតិ ព្រមទាំងចងក្រងអត្ថបទទាំងនេះជាសៀវភៅសំរាប់ផ្សព្វផ្សាយអោយបានទូលំទូលាយ ។

-សហការជាមួយគណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ អន្តរជាតិ និង ស្ថាប័នពាក់ព័ន្ធ រៀបចំទិវាវប្បធម៌ជាតិ នៅថ្ងៃទី០៣ មេសា នៅរាជធានីភ្នំពេញ អោយបានទទួលលទ្ធផលល្អប្រសើរ ។

-ណែនាំមន្ត្រីវប្បធម៌ និង វិចិត្រសិល្បៈ ខេត្ត-ក្រុងអោយផ្សព្វផ្សាយអត្ថបទខាងលើនេះ អោយបានជ្រួតជ្រាបដល់មូលដ្ឋាន និងសំដែងសិល្បៈជូនប្រជារាស្ត្រទស្សនាកំសាន្ត តាមទីសាធារណៈ ព្រមទាំងបំផុសចលនាប្រជាជនចូលរួមកាត់តែងពិធីលេងល្បែងប្រជាប្រិយរបស់ជាតិ រាំកំសាន្តនៅតាមទីកន្លែងដែលមានប្រាសាទបុរាណ រមណីយដ្ឋាន វត្តអារាម ទីប្រជុំជន តាមទំនៀមទំលាប់របស់តំបន់នីមួយៗ ។

-ធ្វើការជ្រើសរើសវីរៈសិល្បករ មានស្នាដៃឆ្នើមប្រចាំឆ្នាំ និងអញ្ជើញវីរៈសិល្បករចាស់ៗ ដែលបានជ្រើសរើសជាវីរៈរាល់ឆ្នាំ តាំងពីឆ្នាំ ១៩៩៣ មកជួបសំណេះសំណាលដើម្បីលើកទឹកចិត្ត ។

៣-ក្រសួងព័ត៌មានរៀបចំផ្សព្វផ្សាយតាមអត្ថបទ ឯកសារ និងបណ្តាសកម្មភាព វប្បធម៌សំខាន់ៗដែលបំរើអោយទិវាវប្បធម៌ជាតិ ០៣មេសា តាមរយៈប្រព័ន្ធឃោសនាជាតិ ពិសេសវិទ្យុ ទូរទស្សន៍ជាតិ វិទ្យុ ទូរទស្សន៍ឯកជន និង សារព័ត៌មាន តាមការពិភាក្សា ឯកភាពជាមួយ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។

៤-ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ត្រូវធ្វើការណែនាំដល់ស្ថានទូតកម្ពុជា នៅបរទេស អោយបំផុសស្មារតី ទិវាវប្បធម៌ជាតិ ០៣មេសា ដល់ប្រជាជនកម្ពុជា នៅបរទេសគ្រប់មូលដ្ឋាន ក្នុងការថែរក្សាការពារអត្តសញ្ញាណជាតិ ដោយយោងទៅតាមឯកសារ ដែលក្រសួងវប្បធម៌ និងវិចិត្រសិល្បៈបានធ្វើការផ្សព្វផ្សាយ។

៥-ក្រសួងអប់រំយុវជន និងកីឡា ក្រសួងធម្មការ និងសាសនា និងក្រសួងទេសចរណ៍ ត្រូវណែនាំព្រះសង្ឃ គ្រូបង្រៀនគ្រប់កំរិតសិក្សា ភ្នាក់ងារមន្ត្រី សិស្សនិស្សិត អោយចូលរួមធ្វើសកម្មភាព ថែរក្សាការពារសំអាតប្រាង្គ

ក្រាលកាប និងវត្តអារាមដែលមានក្នុងមូលដ្ឋានរបស់ខ្លួន អោយបានផុលផុសល្អប្រសើរ ។ ជាពិសេសត្រូវបំផុសអោយសរសេរកំណាព្យ គួរគំនូរ បំរើអោយខ្លឹមសារក្នុងកិច្ចការពារថែរក្សាបេតិកភ័ណ្ឌជាតិ ។

៦-ក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ ត្រូវមានផែនការណែនាំដល់អង្គភាពក្រោមឱវាទ គ្រប់ខេត្ត-ក្រុង បង្កើនកិច្ចការពារ បេតិកភ័ណ្ឌជាតិ ជាប្រចាំនិងថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់ បង្កអោយការរៀបចំ ពិធីទិវាវប្បធម៌ជាតិ ០៣មេសា បានសំរេចការកិច្ចប្រកបដោយក្តីសប្បាយរីករាយ និងសុវត្ថិភាពបរិបូរណ៍ ។

ទទួលបានសារាចរនេះ គ្រប់ក្រសួង ស្ថាប័ន និង អាជ្ញាធរ គ្រប់ខេត្ត-ក្រុង ត្រូវសហការជាមួយក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ដើម្បីបានឯកសារយកទៅចាត់ចែងអនុវត្តរៀបចំ ទិវាវប្បធម៌ជាតិ ០៣មេសា លើកទី២ នេះអោយសំរេចបានលទ្ធផលល្អប្រសើរ ។

នាយករដ្ឋមន្ត្រី
ហត្ថលេខា និងត្រា
ហ៊ុន សែន

***

# ពាក្យស្លោក

---

១-ជយោ ! សម្តេចឪព្រះបិតា បេតិកភណ្ឌជាតិ

២-អបអរសាទរ " ទិវាវប្បធម៌ជាតិ ០៣ មេសា " លើកទី២

៣-ជយោ ! វប្បធម៌សន្តិភាព

៤-វប្បធម៌រុងរឿង ជាតិថ្កុំថ្កើង

៥-បំផ្លាញបេតិកភណ្ឌជាតិ គឺបំផ្លាញខ្លួនឯង

៦-រក្សាការពារបេតិកភណ្ឌ គឺលើកស្ទួយវប្បធម៌ជាតិ

៧-បាត់ថ្មប្រាសាទ គឺបាត់ព្រលឹងជាតិ

៨-លួចគាស់លក់ថ្មប្រាសាទបុរាណ គឺលក់ជាតិ

៩-ប្តេជ្ញាការពារបេតិកភណ្ឌជាតិ

១០-ប្រាសាទ និងវត្ថុបុរាណខ្មែរ ជាបេតិកភណ្ឌវប្បធម៌ជាតិ

១១-វត្ថុ និងគំនូរចម្លាក់បុរាណ ជាបេតិកភណ្ឌជាតិ

***

## II- ការងារបណ្ដាក្រសួង
## និស្ដីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និងថាមពល
## ប្រកាស

រាជធានីភ្នំពេញ,ថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០០០

**ប្រកាស លេខ ១៨៣ កឧ . ប្រក**

**រដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល**

***

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ របស់ព្រះករុណា ព្រះបាទសម្ដេច នរោត្តម សីហនុ ព្រះចៅក្រុងកម្ពុជាធិបតី ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

-បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែ មេសា ឆ្នាំ ១៩៩៩ របស់រាជរដ្ឋាភិបាលកម្ពុជា ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ ក្រសួងឧស្សាហកម្មរ៉ែ និងថាមពល ។

-បានឃើញលិខិតលេខ ០២៧/០០ គ.វ.ក ចុះថ្ងៃទី ០៦.០១.២០០០ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

-បានឃើញលិខិតលេខ ១៩៥ ប.ស្ថសណ ចុះថ្ងៃទី ០៣.០៣.២០០០ របស់ក្រសួងបរិស្ថាន

-បានឃើញការឯកភាពលើប្លង់សាងសង់អាគាររោងចក្រកាត់ដេរ ចុះថ្ងៃទី២៩.១១.១៩៩៩ របស់សាលាខេត្តកណ្ដាល

-យោងពាក្យស្នើរបស់ក្រុមហ៊ុន វីនស្តារ ហ្គាមេន អិនដាសស្ទ្រី ចុះថ្ងៃទី២៨.០២.២០០០ ។

**សំរេច**

**ប្រការ ១ :** អនុញ្ញាតអោយក្រុមហ៊ុន "វីនស្តារ ហ្គាមេន អិនដាសស្ទ្រី" ( VINSTAR GARMENT INDUSTRY Co,LTD) តំណាងដោយលោកស្រី JANG YEN FAN សញ្ជាតិចិន (តៃវ៉ាន់) ភេទស្រី អាយុ ៣៩ឆ្នាំ កាន់លិខិតឆ្លងដែនលេខM12873722 ចុះថ្ងៃទី01.10.1996 បង្កើត រោងចក្រកាត់ដេរសំលៀកបំពាក់នាំចេញ ដែលមានផ្លាកឈ្មោះថា " រោងចក្រ វីនស្តារ ហ្គាមេន អិនដាសស្ទ្រី " មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៥ ភូមិពោធិមង្គល ឃុំព្រែកតាទែន ស្រុកពញាឮ ខេត្តកណ្ដាល ។

**ប្រការ ២ :** ការរៀបចំអាគារ និងគ្រឿងចក្រ ក្រុមហ៊ុន ត្រូវធ្វើទៅតាមប្លង់ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល អោយបានសំរេចក្នុងរយៈពេល ០៦ខែ ដោយរាប់បញ្ចូលទាំងរយៈពេលដំណើរការសាកល្បងផង ។

ប្រការ ៣ : រោងចក្រនេះត្រូវបានអនុញ្ញាតអោយ "កាត់-ដេរសំលៀកបំពាក់ " ទៅតាមគំរូដែលគេកល់ទុក ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែ អំពីស្ថានភាពផលិតកម្មរបស់រោងចក្រ ជូនក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

ប្រការ ៤ : ក្រុមហ៊ុន ត្រូវលើកបង្ហាញ "ផ្លាកឈ្មោះរោងចក្រ " របស់ខ្លួនជាអក្សរខ្មែរ មានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

ប្រការ ៥ : រាល់ការនាំចេញផលិតផលសំរេច ក្រុមហ៊ុនត្រូវសុំវិញ្ញាបនប័ត្របញ្ជាក់ផលិតកម្ម ពីក្រសួង ឧស្សាហកម្ម រ៉ែ និងថាមពល ។

ប្រការ ៦ : ក្រុមហ៊ុន ត្រូវធានាសុវត្ថិភាពឧស្សាហកម្ម និងគុណភាពផលិតផល ព្រមទាំងត្រូវគោរពអោយបានម៉ឺងម៉ាត់នូវច្បាប់ស្តីពីការងារ ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ និងច្បាប់បទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងផលិតកម្ម អាជីវកម្មរបស់ក្រុមហ៊ុន ។

ប្រការ ៧ : ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

ប្រការ ៨ : អគ្គនាយកឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប្រធានមន្ទីរឧស្សាហកម្មរ៉ែ និងថាមពលខេត្តកណ្តាល និងប្រធានក្រុមហ៊ុន វិនស្តារ ហ្គាមេន អ៊ិនដាស្ទ្រី ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

ប្រការ ៩ : ប្រកាសនេះ មានអនុភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ហត្ថលេខា និងត្រា

ស៊ុយ សែម

★★★

រាជធានីភ្នំពេញ,ថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០០០

**ប្រកាស លេខ ១៩៨ កឧ . ប្រក**

**រដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល**

***

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ របស់ព្រះករុណាព្រះបាទសម្តេច **នរោត្តម សីហនុ** ព្រះចៅក្រុងកម្ពុជាធិបតី ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

-បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែ មេសា ឆ្នាំ ១៩៩៩ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្មរ៉ែ និងថាមពល ។

-បានឃើញលិខិតលេខ ២៩៦៩/៩៩ គ.វ.ក ចុះថ្ងៃទី ១៧.១២.១៩៩៩ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-បានឃើញលិខិតលេខ ១១០ ប.ស្ត សណក ចុះថ្ងៃទី ១០.០២.២០០០ របស់ក្រសួងបរិស្ថាន
-បានឃើញកិច្ចសន្យាជួលទីតាំងសាខារោងចក្រកៅស៊ូកង់ទី១ ចុះថ្ងៃទី ២៦.៧.១៩៩១ រវាងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងលោក ឈុនទី ។
-យោងពាក្យស្នើរបស់ក្រុមហ៊ុន ហ្គ្រេត យូញៀន (ខេមបូឌា) ហ្គាមេន ខូអិលធីឌី ចុះថ្ងៃទី០៩.៣.២០០០ ។

## សំរេច

ប្រការ ១ : អនុញ្ញាតអោយក្រុមហ៊ុន ហ្គ្រេត យូញៀន (ខេមបូឌា) ហ្គាមេន ខូអិលធីឌី (GREAT UNION (CAMBODIA) GARMENT Co,LTD) តំណាងដោយលោក LAM SIU MAN សញ្ជាតិចិន (ហុងកុង) ភេទប្រុស អាយុ ៥៨ឆ្នាំ កាន់លិខិតឆ្លងដែនលេខD210489 (0) ចុះថ្ងៃទី21.01.1992 បង្កើតរោងចក្រកាត់ដេរសំលៀកបំពាក់នាំចេញ ដែលមានផ្លាកឈ្មោះថា " រោងចក្រកាត់ដេរ ហ្គ្រេតយូញៀន (ខេមបូឌា) ហ្គាមេន " មានទីតាំងស្ថិតនៅ អាគារ B,D,E ក្នុងបរិវេណអតីតសាខារោងចក្រកៅស៊ូកង់ទី១ ឡូត៍លេខ ៦២៦ ផ្លូវជាតិលេខ២ សង្កាត់ចាក់អង្រែក្រោម ខ័ណ្ឌមានជ័យ រាជធានីភ្នំពេញ ។

ប្រការ ២ : ក្រុមហ៊ុន ត្រូវរៀបចំរោងចក្រទៅតាមប្លង់ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

ប្រការ ៣ : រោងចក្រនេះត្រូវបានអនុញ្ញាតអោយ "កាត់-ដេរសំលៀកបំពាក់ " ទៅតាមគំរូដែលតំកល់ទុក ហើយត្រូវធ្វើរបាយការណ៏ប្រចាំខែ អំពីស្ថានភាពផលិតកម្មរបស់រោងចក្រ ជូនក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

ប្រការ ៤ : ក្រុមហ៊ុន ត្រូវលើកបង្ហាញ "ផ្លាកឈ្មោះរោងចក្រ " របស់ខ្លួនជាអក្សរខ្មែរ មានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

ប្រការ ៥ : រាល់ការនាំចេញផលិតផលសំរេច ក្រុមហ៊ុនត្រូវសុំវិញ្ញាបនប័ត្របញ្ជាក់ផលិតកម្ម ពីក្រសួង ឧស្សាហកម្ម រ៉ែ និងថាមពល ។

ប្រការ ៦ : ក្រុមហ៊ុន ត្រូវធានាសុវត្ថិភាពឧស្សាហកម្ម និងគុណភាពផលិតផល ព្រមទាំងត្រូវគោរពអោយបានម៉ឺងម៉ាត់នូវច្បាប់ស្តីពីការងារ ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ និងច្បាប់បទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងផលិតកម្ម អាជីវកម្មរបស់ក្រុមហ៊ុន ។

ប្រការ ៧ : ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

ប្រការ ៨ : អគ្គនាយកឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប្រធានមន្ទីរឧស្សាហកម្មរ៉ែ និងថាមពលរាជធានីភ្នំពេញ និងប្រធានក្រុមហ៊ុន ប្រេត្ត ឃ្លេញវ៉ុន (ខេមបូឌា) ហ្គាមេន ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

ប្រការ ៩ : ប្រកាសនេះ មានអនុភាពតពិលេបត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខា និងព្រា

ស៊ុយ សែម

★★★